# មិត្តនគរបាល

POLICEFRIENDSHIPMAGAZINE

ទស្សនាវដ្ដី

លេខ ១០៩/ មករា-កុម្ភៈ / ២០២៣

## អរគុណសន្តិភាព










យើងត្រូវរួមគ្នាទៅទទួលការចាក់វ៉ាក់សាំងប្រឆាំងកូវីដ១៩ តាមការកំណត់របស់ រាជរដ្ឋាភិបាលផង រួមគ្នាបន្តអនុវត្ត ៣ការពារ និង ៣កុំ ផង ដើម្បីខ្លួនយើង ក្រុមគ្រួសារយើង និងសង្គមជាតិយើង

# គណៈកម្មការនិពន្ធ

**នាយកគ្រប់គ្រង**

**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ម៉ៅ ប៊ុនណារិន**

**និពន្ធនាយក**

ឧត្តមសេនីយ៍ឯក សៀង សុវត្ថិ

**និពន្ធនាយករង**

ឧត្តមសេនីយ៍ទោ ប៉ុក សុជាតិ

វរសេនីយ៍ឯក ប៉ុក រដ្ឋា




**យកព័ត៌មាន និពន្ធ**

-វរសេនីយ៍ទោ ចាប ភ័ស្ត (ប្រធានក្រុម)
-វរសេនីយ៍ត្រី ប៉ុក គន្ធារ៉ូ
-អនុសេនីយ៍ឯក គន សេរី

**ថតរូប**

-វរសេនីយ៍ទោ ជិន ម៉ូលីដា (ប្រធានក្រុម)
-អនុសេនីយ៍ឯក ស្រ៊ី ឈុនឡេង
-អនុសេនីយ៍ឯក លន់ ឈាងសេង
-អនុសេនីយ៍ឯក ព្រំ ចាន់តារា

**ចែកផ្សាយ**

-វរសេនីយ៍ទោ ង៉ាន សុផាប (ប្រធានក្រុម)
-វរសេនីយ៍ត្រី សុន សៀង

**រចនាទំព័រ**

-អនុសេនីយ៍ឯក ម៉ុង រិទ្ធី (ប្រធានក្រុម)
-អនុសេនីយ៍ឯក អ៊ុន ពិសិទ្ធ

**ពិនិត្យអក្ខរាវិរុទ្ធ**

-វរសេនីយ៍ទោ ញឹម ហឿន (ប្រធានក្រុម)
-អនុសេនីយ៍ឯក វ៉ាន់ វិបុល

**កីឡា និងសិល្បៈ**

-វរសេនីយ៍ត្រី ជឹម ធី (ប្រធានក្រុម)
-អនុសេនីយ៍ឯក មុត សីហា






# មាតិកា

## ព័ត៌មានថ្នាក់ដឹកនាំ


១-សម្តេចតេជោ អញ្ជើញជាអធិបតី...........................១

២-នាយករដ្ឋមន្ត្រីស្តីទី អញ្ជើញ ដឹកនាំកិច្ចប្រជុំ............៧

៣-អគារអង្គភាពនគរបាលការពារបេតិកភណ្ឌ ............៩

៤-សម្តេចក្រឡាហោម អញ្ជើញជាអធិបតីក្នុង........... ១៣

៥-គ្រោះថ្នាក់ចរាចរណ៍ឆ្នាំ២០២២ កើនឡើង ............ ១៥

៦-សន្និបាតបូកសរុបត្រួតពិនិត្យ លទ្ធផលការងារ..............១៩

៧-សម្ពោធដាក់ឱ្យប្រើប្រាស់ សមិទ្ធផលថ្មី.....................២១

៨-កិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យពិភាក្សា.................២៥

៩-ពិធីបិទកិច្ចប្រជុំពិភាក្សា និង ផ្សព្វផ្សាយស្តីពី............២៧

១០-ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត...............២៩

១១-ប្រជុំផ្សព្វផ្សាយអំពីការរៀបចំ និងការប្រព្រឹត្ត........៣១

១២-ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ ទទួល........ ៣៥

១៣-បិទវគ្គបណ្តុះបណ្តាល ស្តីពី តួនាទីភារកិច្ច............ ៣៧

១៤-ក្រសួងមហាផ្ទៃ ពិនិត្យពិភាក្សា ស្តីពីគម្រោង.........៣៩

១៥-ឧត្តមសេនីយ៍ឯក ស ថេត ទទួលជួបពិភាក្សា...........៤៣

១៦-ខែកុម្ភៈបង្ក្រាបគ្រឿងញៀនបាន ៥៨០ករណី..........៥១

១៧-នគរបាលរាជធានីភ្នំពេញ បង្ក្រាបបទល្មើស............៥៥

១៨-សម្តេចក្រឡាហោម អនុញ្ញាតឲ្យឯកអគ្គរាជទូត.......៦៣


## អត្ថបទស្រាវជ្រាវ


១- ដើមឆ្នាំ ២០២៣ គ្រោះមហន្តរាយធម្មជាតិរញ្ជួយដី ..............៤៧

២- មហាសង្ក្រាន្ត ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧.............៥៥


## សកម្មភាពសមាគមមិត្តនគរបាលជាតិកម្ពុជា


១- ប្រគល់ថវិកា ស ម ន..............................................................៥៧




# សម្តេចតេជោ អញ្ជើញជាអធិបតី
## លទ្ធផលការងារឆ្នាំ ២០២២ និងលើកទិសដៅ

បន្ទាប់ពីដំណើរការរបស់រយៈពេលមួយថ្ងៃកន្លះរួចមក នារសៀលថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ កន្លងមកនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ និងលទ្ធផលការងារប្រឡងប្រណាំងអនុវត្តគោលនយោបាយ«**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**» នៅសណ្ឋាគារ **រ៉ស៊ីនដ៍សុខាភ្នំពេញ** ។





នៅក្នុងសុន្ទរកថាស្វាគមន៍ និងរបាយការណ៍របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាន



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




# ដំខួនដំខួសក្នុនពិធីបិទសន្និបាតត្រួតពិនិត្យ ការងារឆ្នាំ ២០២៣ របស់ក្រសួងមហាផ្ទៃ

បញ្ជាក់ថា៖ អង្គសន្និបាតទាំងមូល សូមផ្ញើការវាយតម្លៃខ្ពស់ចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ក្នុងការសម្របសម្រួលដឹកនាំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធធ្វើឱ្យកម្ពុជាយើងសម្រេចបានជោគជ័យយ៉ាងត្រចះត្រចង់ជាប្រវត្តិសាស្ត្រ ក្នុងការបំពេញតួនាទីជាប្រធានប្តូរវេនក្នុងឆ្នាំ២០២២ កន្លងទៅនេះ ដែលបានលើកកម្ពស់នូវកិត្យានុភាពរបស់កម្ពុជាយើង ទាំងនៅក្នុងតំបន់ និងលើឆាកអន្តរជាតិ ។ ទន្ទឹមនឹងនេះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ក៏បានដឹកនាំប្រទេសជាតិ ពុះពារ ឆ្លងកាត់នូវវិបត្តិ និងបញ្ហាប្រឈមនានាជាសកលដែលបាន និងកំពុងវិវត្តន៍ប្រែប្រួលដ៏ស្មុគស្មាញបំផុត ប្រកបដោយជោគជ័យ ដោយ

០៣







៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា












តមកពីទំព័រ ០២

## សម្តេចតេជោ អញ្ជើញជាអធិបតី

ខិតខំស្តារ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ដែលរងផលប៉ះពាល់ពីវិបត្តិជាសកល ធ្វើឱ្យស្ទុះឡើងលឿនយ៉ាងឆាប់រហ័ស ជាមួយនឹងអត្រាកំណើនប្រមាណ៥,២% ក្នុងឆ្នាំ២០២២ ។

ចូលរួមក្នុងសមិទ្ធផលខាងលើនេះ កម្លាំងនគរបាលជាតិ អាវុធហត្ថ និងកងកម្លាំងមានសមត្ថកិច្ចនានាបានសហការគ្នាយកអស់កម្លាំងកាយប្រាជ្ញាស្មារតីខិតខំរក្សាការពារសន្តិសុខ និងសុវត្ថិភាពបានយ៉ាងល្អប្រសើរក្នុងអំឡុងពេលនៃការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដើរទន្ទឹមនឹងការខិតខំលើកកម្ពស់ស្មារតីទទួលខុសត្រូវខ្ពស់ជាប់ជាប្រចាំក្នុងការចូលរួមថែរក្សាពង្រឹងសន្តិភាព ស្ថេរភាពនយោបាយ ការការពារបូរណភាពទឹកដី អធិបតេយ្យភាពជាតិ និងទប់ស្កាត់រាល់ឧបាយកលប៉ុនប៉ងបង្កភាពចលាចលវឹកវរក្នុងសង្គមដោយក្រុមប្រឆាំងជ្រុលនិយម និងជនអគតិនានា ព្រមទាំងខិតខំលើកកម្ពស់ការថែរក្សាការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងសង្គមបានយ៉ាងល្អប្រសើរ ។













សុន្ទរកថាស្វាគមន៍ បានបញ្ជាក់ទៀតថា៖ ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានខាងលើនេះ អង្គសន្និបាតក៏បានកត់សម្គាល់អំពីបញ្ហាប្រឈម ដែលនៅសេសសល់ ពិសេសវិបត្តិ និងបញ្ហាប្រឈមបណ្តាលមកពីការវិវត្តប្រែប្រួលដ៏ស្មុគស្មាញ ឆាប់រហ័ស និងពិបាកប៉ាន់ស្មាននៃស្ថានភាពការណ៍សកលលោក ដែលធ្វើឱ្យប៉ះពាល់មកលើស្ថានភាពការណ៍សន្តិសុខក្នុងតំបន់ និងសកលលោក ដែលក្នុងនោះរួមមាន៖ អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសបច្ចេកវិទ្យា និងបញ្ហាគ្រឿងញៀនខុសច្បាប់ ដែលអាចនឹងវិវត្តប្រែប្រួលកាន់តែស្មុគស្មាញថែមទៀត ។

ផ្អែកលើបញ្ហាប្រឈមដែលសេសសល់ អង្គសន្និបាតបានពិភាក្សាអំពីដំណោះស្រាយសមស្របនានា ជាមួយការពង្រឹងការប្តេជ្ញាចិត្តរួមគ្នាបន្តថែរក្សាការពារឱ្យបាននូវសុខសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ខិតខំរួមគ្នាធានាឱ្យការបោះឆ្នោតជាតិលើកទី៧ ប្រព្រឹត្តទៅប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ មានសុវត្ថិភាពយ៉ាងល្អប្រសើរ ព្រមទាំងចូលរួមរក្សាសុវត្ថិភាពទាំងស្រុងនូវព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅកម្ពុជា ដើម្បីមោទនភាពរបស់ជាតិយើង ។

អញ្ជើញផ្តល់អនុសាសន៍ក្នុងពិធីបិទសន្និបាតពេលនោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានផ្តល់នូវគោលការណែនាំសំខាន់មួយចំនួនបន្ថែមលើទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ដែលមានជាអាទិ៍៖

ត្រូវបន្តពង្រឹង និងថែរក្សាការពារសន្តិភាព ស្ថេរភាពនយោបាយ បូរណភាពទឹកដី អធិបតេយ្យជាតិ ការពារព្រះមហាក្សត្រ ការពាររបបរាជានិយមអាស្រ័យ

០៥



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា













តមកពីទំព័រ ០៤

**សម្តេចតេជោ អញ្ជើញជាអធិបតី...**

រង្គធម្មនុញ្ញ ព្រមទាំងបន្តលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសេរីពហុបក្ស សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋនិងការពង្រឹងនីតិរដ្ឋ ព្រមទាំងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ជាពិសេសឆ្នាំ២០២៣នេះ ព្រះរាជាណាចក្រកម្ពុជា នឹងមានព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រសំខាន់ៗ រួមមានបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ និងការរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេម លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេម លើកទី១២ ។

ចំពោះការរៀបចំការបោះឆ្នោត ក្រសួងស្ថាប័ន អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចនានា ត្រូវផ្តល់កិច្ចសហប្រតិបត្តិការឱ្យបានល្អជាមួយ គ.ជ.ប ស្របតាមច្បាប់ និងនីតិវិធីនៃការបោះឆ្នោត និងត្រូវបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយនានាក្នុងការធ្វើសកម្មភាពក្នុងសង្គម និងសកម្មភាពចូលរួមក្នុងការបោះឆ្នោតជាតិ លើកទី៧នាពេលខាងមុខសំដៅរួមគ្នាធានាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តិទៅប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ បរិយាកាស សន្តិសុខសុវត្ថិភាពល្អប្រសើរ ។

ព្រមជាមួយនោះចំពោះព្រឹត្តិការណ៍កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ក្រសួងស្ថាប័ន អាជ្ញាធរ និងកងកម្លាំង



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

មានសមត្ថកិច្ចនានា ត្រូវខិតខំរួមគ្នារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពឱ្យបានល្អប្រសើរ ក្នុងអំឡុងពេលរៀបចំព្រឹត្តិការណ៍ទាំងនេះ រួមទាំងសុវត្ថិភាពចំពោះកីឡាករ និងអ្នកចូលរួមទាំងក្នុង និងក្រៅប្រទេសស្របតាមផែនការដែលបានកំណត់ ។ ក្នុងនោះរដ្ឋបាលរាជធានី-ខេត្ត ត្រូវជំរុញការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ សោភ័ណភាព និងអនាម័យឱ្យបានល្អប្រសើរ ដើម្បីលើកកម្ពស់មុខមាត់ និងកិត្តិយសរបស់ជាតិយើង ។





**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ក៏បានមានប្រសាសន៍ណែនាំដល់កងកម្លាំងនគរបាលជាតិ ត្រូវខិតខំបន្តអភិវឌ្ឍសមត្ថភាពនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការទាំងក្នុងតំបន់ និងអន្តរជាតិ ដើម្បីបង្កើនការទប់ស្កាត់ បង្ក្រាបឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពនូវអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសបច្ចេកវិទ្យា សកម្មភាពជួញដូរមនុស្សគ្រប់ទម្រង់ និងបទល្មើសនានាឆ្លងកាត់ព្រំដែនគ្រប់ប្រភេទ ព្រមទាំងបន្តជំរុញការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការបង្ការទប់ស្កាត់បង្ក្រាបបទល្មើសនានាក្នុងសង្គម ជាពិសេសបទល្មើសលួច ឆក់ ប្លន់ ល្បែងស៊ីសងខុសច្បាប់ គ្រឿងញៀនខុសច្បាប់ អំពើហិង្សាក្នុងគ្រួសារ និងក្រុមក្មេងទំនើង នៅតាមមូលដ្ឋាន ៕











៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# នាយករដ្ឋមន្ត្រីស្តីទី អញ្ជើញដឹកនាំកិច្ចប្រជុំ សណ្តាប់ធ្នាប់សម្រាប់ការប្រកួតកីឡាស៊ីហ្គេម លើកទី

កាលពីព្រឹកថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី បានអញ្ជើញដឹកនាំកិច្ចប្រជុំ ស្តីពីកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងពិធីប្រកួតកីឡាស៊ីហ្គេម លើកទី៣២ និងកីឡាជនពិការអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ នៅទីស្តីការក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ ឯកឧត្តម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ ឯកឧត្តម អគ្គនាយក ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការរង កងយោធពលខេមរៈភូមិន្ទនិងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ឯកឧត្តម អភិបាលរាជធានីភ្នំពេញ







៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ពិនិត្យផែនការស្ដីពីការការពារសន្តិសុខ
# ៣២ និង អាស៊ានប៉ារ៉ាហ្គេមលើកទី ១២ ឆ្នាំ ២០២៣





និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀត ។

**សម្ដេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់ថា៖ ព្រឹត្តិការណ៍ស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៅឆ្នាំ២០២៣នេះនឹងមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំ ប្រតិភូកីឡា និងមហាជនជាតិ និងអន្តរជាតិជាច្រើន ដែលបញ្ហានេះទាមទារឱ្យមានការពង្រឹងសន្តិសុខ និងសណ្ដាប់ធ្នាប់បានល្អប្រសើរ ដើម្បីរួមចំណែកធ្វើឱ្យព្រឹត្តិការណ៍នេះទទួលបានជោគជ័យ ។

**សម្ដេចក្រឡាហោម** មានប្រសាសន៍បន្តទៀតថា៖ ព្រះរាជាណាចក្រកម្ពុជាបានខកខានរៀបចំព្រឹត្តិការណ៍កីឡានេះជាច្រើនឆ្នាំមកហើយ ក្រោយពីបានចូល

៤១



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# អគារអង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំ





នាព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ អគារអង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំតំបន់អង្គរប្រាសាទនៅខេត្តសៀមរាប ។

លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអញ្ជើញថ្លែងរបាយការណ៍ស្វាគមន៍ ជូន **សម្តេចក្រឡាហោម** និងអង្គពិធីជ្រាបថា ៖ អគារថ្មីនេះ ជាសមិទ្ធផលថ្មីមួយទៀតកើតចេញពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងអាជ្ញាធរជាតិអប្សរា អង្គភាពនគរបាលការពារបេតិកភណ្ឌ ក្រោមការគាំទ្ររបស់អគ្គស្នងការដ្ឋាននគរបាលជាតិ អាជ្ញាធរខេត្ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធមួយចំនួនទៀត ។



**៣ការពារ ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# តំបន់អង្គរត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ





លោកជំទាវ រដ្ឋមន្ត្រីក្រសួងវប្បធម៌ បញ្ជាក់ទៀតថា៖ អគារថ្មីរបស់អង្គភាពនគរបាលការពារបេតិកភណ្ឌ ត្រូវបានសាងសង់ឡើងលើផ្ទៃដីដោះត្រាយ គោលនយោបាយរួមរបស់អាជ្ញាធរជាតិអប្សរា ដែលមានផ្ទៃក្រឡាសរុប ១៩.៩៤៧ ម៉ែត្រការ៉េ មានតម្លៃសរុបប្រមាណ ៧ប៊ីលាន ១៩៨លានរៀល ជាថវិកាបានមកពីមូលនិធិអភិរក្សឆ្នាំ២០១៨ នៃអាជ្ញាធរជាតិអប្សរា ។ ទីតាំងនេះត្រូវបានបែងចែករួមមានអគារថ្នាក់ដឹកនាំ សាលប្រជុំ បន្ទប់ស្នាក់នៅរបស់ប្រធានអង្គភាព អគារអនុប្រធានអង្គភាព និងផ្នែកព្រហ្មទណ្ឌ អគារសុខាភិបាលនិងវិទ្យុ អគារស្នាក់នៅរបស់កងកម្លាំងអន្តរាគមន៍ អគារផ្ទះបាយ ជម្រកកម្លាំងត្រៀម រោងចំណតម៉ូតូ រោងចំណតរថយន្តអគ្គិភ័យ ប៉ុស្តិ៍យាម ដងទង់ជាតិ ចំណតរថយន្តតូច ទីលានកីឡា ស្រះទឹក និងអង់តែនវិទ្យុទាក់ទងជាដើម ។

☞ ១១



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា








តមកពីទំព័រ ១០

**អគារអង្គភាពនគរបាលការពារបេតិកភណ្ឌ......**

អញ្ជើញមានប្រសាសន៍សំណេះសំណាលក្នុងពិធីនេះ **សម្តេចក្រឡាហោម** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិក ភ្នាក់ងារពលករ ឆ្មាំ មន្ត្រីរាជការ និងថ្នាក់ដឹកនាំទាំងអស់នៃអាជ្ញាធរជាតិអប្សរាក្នុងបុព្វហេតុអភិរក្ស និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ ជាពិសេសគំនិតផ្តួចផ្តើមសិក្សារៀបចំ និងកែលម្អថ្មីជាមួយនឹងការលេចឡើងនូវសមិទ្ធផលជាច្រើន ដែលធ្វើឲ្យអគារថ្មីរបស់អង្គភាពនគរបាលការពារបេតិកភណ្ឌពេលនេះពិតជារៀបចំបានស្អាតតាមរចនាបទប្លង់ស្ថាបត្យកម្មខ្មែរសាមញ្ញ ប៉ុន្តែបានបង្កប់នូវភាពថ្លៃថ្នូរសក្តិសមជាសមិទ្ធផលថ្មី និងជួយបង្កើនសោភ័ណ្ឌភាពរមណីយដ្ឋាននិងភាពថ្លៃថ្នូរព្រមទាំងជាសុខភាពជូនកងកម្លាំងនគរបាលការពារបេតិកភណ្ឌ។

**សម្តេចក្រឡាហោម** មានប្រសាសន៍បន្តថា៖ រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយតាមគោលការណ៍ស្ម័គ្រចិត្ត និងផ្លាស់ប្តូរទីលំនៅរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅមិនរៀបរយក្នុងតំបន់រមណីយដ្ឋានទៅកាន់ភូមិធម្មជាតិរុនតាឯក និងតំបន់ពាក់ស្នែង ហើយប្រជាពលរដ្ឋជាច្រើនពាន់គ្រួសារបានស្ម័គ្រចិត្ត ចូលរួមដែលជាការ បង្ហាញអំពីគុណធម៌ភាព និងការដឹងគុណចំពោះមរតកដូនតាដ៏មានតម្លៃមហាសាលនេះ ។

**សម្តេចក្រឡាហោម** បានផ្តល់អនុសាសន៍ឱ្យអាជ្ញាធរខេត្តសៀមរាប និងអង្គភាពនគរបាលការពារបេតិកភណ្ឌ បន្តសហការជិតស្និទជាមួយអាជ្ញាធរជាតិអប្សរាក្នុងកិច្ចការថែរក្សាការពារបេតិកភណ្ឌជាតិ ពិសេសកិច្ចការស្រាវជ្រាវ និងអនុវត្តវិធានការបង្ការទប់ស្កាត់និងបង្ក្រាបរាល់អំពើខុសច្បាប់ ការបំផ្លិចបំផ្លាញ ការជីកកកាយវត្ថុបុរាណ ការកាប់បំផ្លាញព្រៃឈើ ការលួចប្លន់ ការទិញលក់ ការដឹកជញ្ជូន ដោយបញ្ជូនជនល្មើស និងវត្ថុតាងទៅតុលាការចាត់វិធានការតាមច្បាប់ ។

**សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍ណែនាំ ឱ្យពិនិត្យការរៀបចំ



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



កំណត់ទីតាំងឈររង់ចាំការពារជាអាទិភាពជាថ្មី និងការចល័តល្បាតពង្រឹងការឃ្លាំមើលមិនអនុញ្ញាតឱ្យមានការចេញចូលតំបន់ហាមឃាត់ជាអាទិភាពនានាចំពោះបុគ្គលិកទាំងឡាយណាដែលពុំមានភារកិច្ច និងគ្មានការអនុញ្ញាតពីអាជ្ញាធរជាតិអប្សរា ពិសេសនៅពេលយប់តាមចំណុចសំខាន់នៃតំបន់រមណីយដ្ឋានអង្គរ និងតំបន់ផ្សេងទៀត សំដៅឆ្លើយតបការអភិវឌ្ឍរីកចម្រើន និងស្ថានភាពប្រែប្រួលល្បិចល្បិចនៃបទល្មើសនានា ។ ទន្ទឹមនេះត្រូវបង្កើនការអប់រំ និងពង្រឹងស្មារតីវិន័យកងកម្លាំង និងមនសិការវិជ្ជាជីវៈស្រលាញ់បេតិកភណ្ឌវប្បធម៌ជាតិ សំដៅ



បង្ការ និងកាត់បន្ថយការចូលរួមប្រព្រឹត្តអំពើអនាធិបតេយ្យនានានៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដូចជាការបោះទីតាំងស្នាក់នៅទីកន្លែងធ្វើអាជីវកម្ម និងសកម្មភាពទាំងឡាយណាដែលបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន និងមិនបានសុំការអនុញ្ញាតស្របច្បាប់ពីអាជ្ញាធរជាតិអប្សរា។ ជាពិសេសត្រូវយកចិត្តទុកដាក់ក្នុងកិច្ចការពារសុវត្ថិភាព សន្តិសុខភ្ញៀវជាតិ និងអន្តរជាតិដែលមកបំពេញបេសកម្ម និងទស្សនៈកិច្ចនៅតំបន់អង្គរនិងតំបន់ផ្សេងទៀត ហើយអាជ្ញាធរខេត្តសៀមរាប អាជ្ញាធរជាតិអប្សរា ព្រមទាំងអង្គភាពនគរបាលការពារបេតិកភណ្ឌត្រូវខិតខំថែរក្សាបរិស្ថានធម្មជាតិ ដែលជាផ្នែកមួយរបស់នៃទេសភាពវប្បធម៌របស់រមណីយដ្ឋានអង្គរ ៕





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# សម្តេចក្រឡាហោម អញ្ជើញជាអធិបតីក្នុងពិធី ផ្សព្វផ្សាយការងារគ្រប់គ្រង ហត្ថពលកម្មបរទេស នៅព្រះរាជាណាចក្រកម្ពុជា





នាព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីផ្សព្វផ្សាយការងារគ្រប់គ្រងហត្ថពលកម្មបរទេសនៅព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ **សុខាភ្នំពេញ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម រដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ឯកឧត្តម អគ្គនាយក ឯកឧត្តម លោកជំទាវ ជាអភិបាលរាជធានី-ខេត្ត តំណាងស្ថានទូត ស្ថានតំណាងប្រទេសនានាប្រចាំកម្ពុជា តំណាងអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងតំណាងសហជីព ជាច្រើនរូប ។



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា៖ ជនបរទេសដែលបានធ្វើបណ្ណការងារ និងសៀវភៅការងារ មានការកើនឡើងពី ៤០០នាក់ នៅឆ្នាំ២០១៣ ដល់ ២០៧.៨៨៦នាក់ នៅឆ្នាំ២០១៩ ខណៈក្រោយវិបត្តិកូវីដ-១៩ មានប្រមាណ ១៨១.៦៥៣នាក់ គិតត្រឹមឆ្នាំ២០២២ ដោយក្រសួងរកចំណូលចូលថវិកាជាតិតាមរយៈការផ្តល់បណ្ណការងារ និងសៀវភៅការងារប្រមាណ២២.៨លានដុល្លារ តាមរយៈការផ្តល់ទិដ្ឋាការការងារ បានប្រមាណ ៦លានដុល្លារ និងតាមរយៈការដាក់ពិន័យ បានប្រមាណ ៧៦ម៉ឺនដុល្លារអាមេរិក ។

ទន្ទឹមនេះ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានគូសបញ្ជាក់អំពីបញ្ហាប្រឈមមួយចំនួន ដូចជាកាស៊ីណូ ក្លឹបកំសាន្ត និងជនបរទេសមួយចំនួនបានលួចលាក់មិនប្រកាសពីចំនួនបុគ្គលិកបរទេស ដោយបានបន្តលាក់បាំងហត្ថពលកម្មបរទេស ការលួចឆ្លងដែនរបស់ជនបរទេសខុសច្បាប់តាមមេខ្យល់ សកម្មភាពល្បែងអនឡាញ ការប្រកាសផ្សព្វផ្សាយការងារបោកប្រាស់ និងចំណុចខ្សោយនៃកិច្ចសហការរវាងអាជ្ញាធរ និងស្ថាប័ន ។



បន្ទាប់ពីបានស្តាប់របាយការណ៍ និងការធ្វើបទបង្ហាញ ជាបន្តបន្ទាប់របស់ ឯកឧត្តម **នៅ លក្ខិណា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និង ឯកឧត្តម **សេង សក្កដា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកនៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈ

៤២



ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# គ្រោះថ្នាក់ចរាចរណ៍ឆ្នាំ ២០២២ កើនឡើង ៣០៦លើក

## បណ្តាលឲ្យអ្នកស្លាប់កើនឡើង ២១២នាក់ ធៀបនិងឆ្នាំ ២០២១




ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

នាព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ ២០២៣ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក(គ.ស.ច.គ) បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ ២០២២ និងទិសដៅការងារឆ្នាំ២០២៣ នៅសាលប្រជុំក្រសួងសាធារណការ និងដឹកជញ្ជូន ។



លោកជំទាវ មឺន មាណាវី រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន





៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



លោកជំទាវ **មឹន មាណវី** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ស.ច.គ បានរាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យរឹតបន្តឹងការអនុវត្តច្បាប់ ក្នុងឆ្នាំ២០២២ ដោយបានត្រួតពិនិត្យយានយន្តសរុប១.១២១.១៣៦គ្រឿង ក្នុងនោះ ប៉ូត្តូ៧៥ភាគរយរកឃើញយានយន្តល្មើសនឹងពិន័យចំនួន១៤៧.៨១៧គ្រឿង ក្នុងនោះទោចក្រយានយន្ត និងត្រីចក្រយានយន្តមានចំនួន១១៥.៨០១គ្រឿង ព្រមទាំងរថយន្តល្មើសចំនួន២៧.០១៦គ្រឿង ក្នុងនោះរថយន្តធុនធ្ងន់មាន ៣.៥៩២គ្រឿង ។



ទន្ទឹមនេះនៅក្នុងឆ្នាំ២០២២ មានគ្រោះថ្នាក់ចរាចរណ៍សរុបកើតឡើង២២.៩៧៦ករណី មានអ្នកស្លាប់១.៧០៩នាក់ របួស៤.០២៦នាក់ ក្នុងនោះធ្ងន់២.៥៧៩នាក់ ខណៈអ្នកស្លាប់ភាគច្រើននៅរាជធានីភ្នំពេញ មានចំនួន២៧២នាក់ ខេត្តកណ្ដាល ១៥៧នាក់ និងខេត្តកំពង់ចាម ១៣១នាក់ ។មូលហេតុនៃគ្រោះថ្នាក់ គឺបើកបរលើសល្បឿន៣៩ភាគរយ មិនគោរពសិទ្ធិអាទិភាព ២៤ភាគរយ មិនប្រកាន់ស្ដាំ ១១ភាគរយ វ៉ាជែង ១០ភាគរយ បត់ក្នុង

☞ ១៧







៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា





តមកពីទំព័រ ១៦

**គ្រោះថ្នាក់ចរាចរណ៍ ឆ្នាំ២០២២ កើនឡើង..**

ស្ថានភាពគ្រោះថ្នាក់ ៩ភាគរយ ស្រវឹង ៤ភាគរយ ងងុយ ១ភាគរយ ។

លោកជំទាវ រដ្ឋលេខាធិការ និងជាអគ្គលេខាធិការ គ.ស.ច.គ បានបញ្ជាក់ទៀតថា៖ ករណីគ្រោះថ្នាក់ចរាចរណ៍ប្រចាំឆ្នាំ២០២២នេះ **បើធៀបនឹងឆ្នាំ២០២១ បានកើនឡើង៣០៦លើក ស្មើនឹង ១១ភាគរយ អ្នកស្លាប់កើន ២១២នាក់** ស្មើ១៤ភាគរយ របួសកើន ៤១១នាក់ ស្មើ១១ភាគរយ ។ ប៉ុន្តែបើធៀបនឹងឆ្នាំ២០១៩ ដែលជាឆ្នាំមានគ្រោះថ្នាក់ចរាចរណ៍ច្រើនបំផុតនោះហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍បានថយ ១.១៤៥ លើក ស្មើ២៨ភាគរយ អ្នកស្លាប់បានថយចុះ ២៧២នាក់ ស្មើនឹង១៤ភាគរយ អ្នករបួសថយចុះ ២.១១៥នាក់ ស្មើនឹង ៣៤ភាគរយ ។

ជាការកត់សម្គាល់អ្នកជួបគ្រោះថ្នាក់ដោយការប្រើប្រាស់ម៉ូតូមាន៤.៤០៣នាក់ ស្មើនឹង៧៧ភាគរយ ក្នុងនោះមិនពាក់មួកសុវត្ថិភាព ៣.០៥៤នាក់ ស្មើនឹង៦៩ភាគរយ ភាគច្រើនមិនពាក់ពេលយប់ ខណៈពេលយប់មានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ៥៧ភាគរយ បណ្តាលឱ្យមនុស្សស្លាប់ ៥៧ភាគរយ របួស៥៤ភាគរយ ធៀបនឹងគ្រោះថ្នាក់ចរាចរណ៍សរុប ។ ដោយឡែកករណីគ្រោះថ្នាក់រថយន្តដឹកកម្មករមាន ១៣លើក ស្លាប់១នាក់ របួសជាង៣៧០នាក់។ បញ្ជូនករណីគ្រោះថ្នាក់ចរាចរណ៍ទៅតុលាការចំនួន ១.០២៧ករណី បានដោះស្រាយចប់១២១ករណី កំពុងអង្កេត៦៤ករណី និងបញ្ជូនជនល្មើសទៅតុលាការ ៣១៦នាក់ ។

ដោយឡែកសភាពការណ៍គ្រោះថ្នាក់ចរាចរណ៍លើផ្លូវល្បឿនលឿនរយៈពេល៣ខែ ពីថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ក៏ត្រូវបានរាយការណ៍ឱ្យដឹងក្នុងកិច្ចប្រជុំនេះដែរ គឺក្នុងរយៈពេល៣ខែកន្លងមកនេះ មានរថយន្តឆ្លងកាត់សរុបចំនួន១.០៥៤.៩៦២ មានគ្រោះថ្នាក់កើតឡើង៣៨លើក ខូចខាតយានយន្ត៤៦គ្រឿង ប៉ុន្តែគ្មានអ្នករងគ្រោះបណ្តាលឱ្យស្លាប់ និងរងរបួសធ្ងន់ធ្ងរនោះទេ ។

អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំនោះដែរ ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ស.ច.ក បានអញ្ជើញថ្លែងនូវចំណាប់អារម្មណ៍លើប្រធានបទសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការធ្វើចរាចរណ៍នៅក្នុងប្រទេសកម្ពុជា និងបានស្នើកិច្ចប្រជុំពិចារណាតម្លើងកម្រិតល្បឿនសម្រាប់រថយន្តលើផ្លូវ ដែលត្រូវបានពង្រីកគន្លង និងបានផ្តល់ព័ត៌មានជូនអង្គប្រជុំអំពីដំណើរការថែទាំផ្លូវថ្នល់ ការស្ថាបនា និងកែលម្អគុណភាពផ្លូវការសិក្សាចប់សព្វគ្រប់នូវដំណើរការសាងសង់ស្ពានព្រែកប្រា-ចាក់អង្រែក្រោម ការសិក្សាផ្លូវដែកល្បឿនលឿនភ្នំពេញ-ប៉ោយប៉ែត ការសិក្សាគម្រោងជីកព្រែកពីទន្លេបាសាក់ទៅកាន់សមុទ្រដើម្បីសម្រួលការដឹកជញ្ជូនតាមផ្លូវទឹក ព្រមទាំងទស្សនា



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




ទាំងមួយចំនួនទៀត ពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក ។

អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំនោះ **សម្តេចក្រឡាហោម** បានសម្តែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ អាជ្ញាធរ កងកម្លាំង មានសមត្ថកិច្ចចំណុះ គ.ស.ច.គ ទាំងការពង្រឹងការអនុវត្តច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តការកសាងផ្លូវសុវត្ថិភាព និងការបំពាក់សម្ភារៈធានាសុវត្ថិភាពចរាចរណ៍ជាដើម ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់បន្ថែមថា៖ គ្រោះថ្នាក់ចរាចរណ៍បានបន្សល់ទុកសោកនាដកម្មជាច្រើនដល់ប្រជាពលរដ្ឋ ដូចជាការរងរបួស ពិការភាព ការខាតបង់ទ្រព្យសម្បត្តិជាឧបសគ្គរារាំងដល់ដំណើរការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ដោយសារអ្នកប្រើប្រាស់ផ្លូវមួយចំនួនមិនគោរពប្រតិបត្តិច្បាប់ ខ្វះសីលធម៌ ខ្វះការយល់ឃើញ អធ្យាស្រ័យ ហាក់ដូចជាមិនសូវស្រឡាញ់ជីវិតខ្លួនឯង និងអ្នកដទៃ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍បញ្ជាក់ទៀតថា៖ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មីនឹងក្លាយជាយន្តការថ្មីមួយទៀត ដើម្បីបង្ខំឱ្យពលរដ្ឋគោរពច្បាប់ ដើម្បីធានាសុវត្ថិភាព ដូចជាយន្តការដកបណ្ណបើកបរក្នុងករណីស្រវឹង ឬមានសារធាតុញៀនជាដើម ។ ដូច្នេះអគ្គស្នងការដ្ឋាននគរបាលជាតិ ពង្រឹងការត្រួតពិនិត្យឯកសារគ្រឿងយន្ត ដោយអាចពិចារណាធ្វើប្រតិបត្តិការឆ្មក់តាមគោលដៅ ប៉ុន្តែមិនត្រូវឱ្យការងារនេះក្លាយជាកុងត្រូលជជុះជាដាច់ខាត។ សម្រាប់ទីតាំងកែច្នៃយានយន្តគ្មានអាជ្ញាបណ្ណ ក៏ត្រូវបិទជាបន្ទាន់ ហើយចាត់វិធានការទៅតាមផ្លូវច្បាប់ និងអនុញ្ញាតឱ្យដំណើរការឡើងវិញ ប្រសិនបើបានរៀបចំត្រឹមត្រូវតាមច្បាប់ និងក្បួនបច្ចេកទេស ។

លើសពីនេះទៀត **សម្តេចក្រឡាហោម** ក៏បានផ្តល់អនុសាសន៍លើកទឹកចិត្តឱ្យក្រុមហ៊ុន ឬអាជីវករលក់ម៉ូតូ ថែមជូនមួកសុវត្ថិភាពដល់អ្នកទិញ ដើម្បីជាការលើកទឹកចិត្ត និងជាការចូលរួមចំណែកបណ្តុះវប្បធម៌គោរពច្បាប់ និងគិតពីសុវត្ថិភាព ។

គួរបញ្ជាក់ឱ្យដឹងដែរថា៖ ពាក់ព័ន្ធដំណើរការសាកល្បងដកពិន្ទុអ្នកបើកបរល្មើសចាប់ពីថ្ងៃទី១ ខែកញ្ញា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ បានត្រួតពិនិត្យដកពិន្ទុបណ្ណបើកបរសរុប៨.៥១៣នាក់ ក្នុងនោះមានស្ត្រី ៥៨៨នាក់ រថយន្តធុនស្រាល ៧.៤៧៧ គ្រឿង ។ ក្នុងចំណោមករណីល្មើសចំនួន ៧.៥៧៩ករណី សមត្ថកិច្ចបានដកពិន្ទុសរុប១០.១៦២ពិន្ទុ ក្នុងនោះរថយន្តធុនធ្ងន់មាន ១.០៣៦គ្រឿង ពិន្ទុដកសរុបជាង ៦០០ពិន្ទុ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សន្និបាតបូកសរុបត្រួតពិនិត្យលទ្ធផល
# ការងារបន្តសម្រាប់ឆ្នាំ ២០២៣

នារសៀលថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៣ កន្លងមកនេះ នៅបណ្ឌិត្យសភានគរបាលកម្ពុជា បានរៀបចំពិធីបិទសន្និបាតបូកសរុបត្រួតពិនិត្យលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារបន្តសម្រាប់ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម សន្តិបណ្ឌិត **ចាន់ អ៊ិន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំ សាស្ត្រាចារ្យគ្រូនគរបាលជាតិ និងមន្ត្រីនៃបណ្ឌិត្យសភានគរបាលកម្ពុជា សរុប ១០៩៣នាក់ បន្ទាប់ពីបានដំណើរការយ៉ាងមមាញឹករបស់រយៈពេលមួយព្រឹកពេញរួចមក ។



ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ សេង ផល្លី ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា





៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




# ការងារប្រចាំឆ្នាំ ២០២២ និងទិសដៅ របស់បណ្ឌិត្យសភានគរបាលកម្ពុជា





ក្នុងសន្ទរកថាស្វាគមន៍របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា បានបញ្ជាក់ឱ្យដឹងថា៖ ដើម្បីសម្រេចបាននូវភារកិច្ចស្នូលរបស់ខ្លួនបណ្ឌិត្យសភានគរបាលកម្ពុជា បានដាក់ចេញនូវផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំដំណាក់កាលទី២ ២០១៩ដល់២០២៣ និងកម្មវិធីកំណែទម្រង់លើការងារសំខាន់ៗទាក់ទងនឹងការដឹកនាំ-គ្រប់គ្រង ការអភិវឌ្ឍកម្មវិធីអប់រំ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងធនធានមនុស្ស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈសិក្សា ការស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល ការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ សំដៅលើកកម្ពស់គុណភាពអប់រំបណ្តុះបណ្តាល និងធានាឱ្យបានគុណភាពលើ

☞ ៤៧



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# សម្ពោធដាក់ឲ្យប្រើប្រាស់សមិទ្ធផលថ្មី



ឧត្តមសេនីយ៍ទោ ម៉ែន លី ស្នងការនគរបាលខេត្តកំពង់ធំ



កាលពីព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣កន្លងមកនេះ នៅស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម បណ្ឌិត **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុម





**៣ការពារ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 9:55 AM



# របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ



ការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការសមិទ្ធផលថ្មីរបស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ។

ឧត្ដមសេនីយ៍ទោ **ម៉ែន លី** ស្នងការនគរបាលខេត្តកំពង់ធំ បានបញ្ជាក់ថា៖ សមិទ្ធផលថ្មីរបស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ដែលត្រូវសម្ពោធដាក់ឲ្យប្រើប្រាស់នាពេលនេះរួមមាន៖ អគារសាល



ប្រជុំ អគារមុខងារ ផ្ទះបាយថ្នាក់ដឹកនាំ និងប្រចាំបញ្ជារបស់កងកម្លាំងអន្តរាគមន៍ រោងរថយន្តចំនួន ០៣កន្លែង អគាររដ្ឋបាល អគារស្នាក់នៅកងអន្តរាគមន៍ ស្នាក់ការប្រចាំបញ្ជា បន្ទប់អនាម័យ អគារប្រឆាំងបទល្មើសសេដ្ឋកិច្ច និងគ្រឿងញៀន ក្លោងទ្វារចំនួន ០២ ប៉ុស្តិ៍យាម របងថ្ម ផ្លូវបេតុងចូលខាងលិច ០១ខ្សែ ចាក់បេតុង

☞ ២៣



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/wvlq/ Page 25 of 68







តមកពីទំព័រ ២២

## សម្ពោធដាក់ឲ្យប្រើប្រាស់សមិទ្ធផលថ្មី ...

ទីផ្លា ទីផ្លាចាក់ក្រាលថ្មខ្មៅ ប្រពន្ធ័លូចំនួន ០៣ខ្សែ បំពាក់សម្ភារ ឧបករណ៍ ម៉ាស៊ីនត្រជាក់ កង្ហារ គ្រឿងបំពងសំលេង គ្រឿងសង្ហារឹម តុ កៅអី ដងទង់ជាតិ និងដាំដើមឈើចម្រុះ មួយចំនួនទៀត សមិទ្ធផលទាំងនេះបានចំណាយថវិកាសម្រាប់សាងសង់ និងជួសជុលសរុបចំនួន ៦៦ម៉ឺន៥ពាន់ ៥៩៨ដុល្លារអាមេរិក ដោយមិនប្រើប្រាស់ថវិការដ្ឋនោះទេ ដោយថវិកានេះ បានមកពីការជួយឧបត្ថម្ភរបស់សប្បុរសជន និងក្រុមហ៊ុននានា តាមរយៈការអំពាវនាវចូលរួមអភិវឌ្ឍន៍កសាងអង្គភាព និងជាពិសេស ឯកឧត្តម នាយឧត្តមសេនីយ៍ **ខេង សុមេធ** អគ្គស្នងការរងនគរបាលជាតិ ដែលតែងតែជួយឧបត្ថម្ភគាំទ្រក្នុងសកម្មភាពសាងសង់នេះ ។

ឯកឧត្តម បណ្ឌិត រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តកំពង់ធំ បានមានប្រសាសន៍ថា៖ សមិទ្ធផលថ្មីរបស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ដែលបានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅពេលនេះ គឺបានបង្ហាញឲ្យឃើញពីចរិតនៃថ្នាក់ដឹកនាំដែលស្រលាញ់ការងារ ស្រលាញ់អង្គភាព ស្រលាញ់កូនចៅដែលជាមន្ត្រីក្រោមឱវាទ ចង់ឲ្យមានកន្លែងធ្វើការងារសមរម្យទទួលបាននូវសោភ័ណភាព ផាសុខភាពមានអនាម័យក្នុងអង្គភាព និងជាពិសេសបានបង្ហាញពីសាមគ្គីភាពទាំងផ្ទៃក្នុងអង្គភាព ទាំងស្ថាប័ន មន្ទីរជុំវិញខេត្ត រួមទាំងសប្បុរសជនជាច្រើន ទើបធ្វើឲ្យស្នងការដ្ឋានប្រែមុខមាត់កាន់តែប្រសើរឡើងបែបនេះ ។ សមិទ្ធផលថ្មីនេះទទួលបាននូវភាពជឿជាក់ពីសំណាក់ប្រជាពលរដ្ឋមកលើកងកម្លាំងនគរបាល តាមរយៈកិច្ចខិតខំប្រឹងប្រែងកសាងអង្គភាពមួយដែលរឹងមាំ និងសំភិតសមជាបង្អែកយ៉ាងពិតប្រាកដ ផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមរបស់បងប្អូនប្រជាពលរដ្ឋ ។

អញ្ជើញមានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានមានប្រសាសន៍បញ្ជាក់អំពីបញ្ហាប្រឈមដែលត្រូវគិតគូរដោះស្រាយចំពោះមុខរបស់គណៈបញ្ជាការឯកភាពខេត្តកំពង់ធំ រួមមាន ៖

**ទី១**.ការព្រួយបារម្ភណ៍របស់ប្រជាពលរដ្ឋពាក់ព័ន្ធ និងបញ្ហាបទល្មើសផ្សេងៗ ដូចជាបទល្មើសលួចឆក់ប្លន់ និងបញ្ហាគ្រឿងញៀន ដែលមិនទាន់មានសញ្ញាថមថយនៅឡើយ ។

**ទី២**.បញ្ហាគ្រោះថ្នាក់ចរាចរណ៍ ដែលមានការកើនឡើង២០ភាគរយ ដែលក្នុងនោះការស្លាប់ និងរបួសក៏មានការកើនឡើង។

**ទី៣**.ត្រូវកែប្រែឥរិយាបថរបស់កងកម្លាំងដែលប្រជាពលរដ្ឋមិនពេញចិត្ត ។

ទន្ទឹមនេះ ថ្នាក់ដឹកនាំនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ត្រូវរួមគ្នាព្យាករណ៍សភាពការណ៍ និងព្រឹត្តិការណ៍នយោបាយ ដើម្បីដាក់ចូលជាទិសដៅ និងសកម្មភាពការងារ រួមមាន ៖

**ទី១**.ត្រៀមការពារព្រឹត្តិការណ៍ជាតិ



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



ធំៗក្នុងនោះ ដូចជាការប្រកួតកីឡាស៊ីហ្គេម និងប៉ារ៉ាហ្គេមនៃលើកម្ពុជា ធ្វើជាម្ចាស់ផ្ទះ កិច្ចការពារការបោះឆ្នោតសកលពិធីបុណ្យទន្លេ និងព្រះរាជពិធីច្រត់ព្រះនង្គ័ល ដែលគ្រោងប្រារព្ធធ្វើនៅក្នុងខេត្តកំពង់ធំ ក្រោមព្រះរាជវត្តមានដ៏ខ្ពង់ខ្ពស់បំផុតនៃអង្គព្រះមហាក្សត្រ ។

**ទី២**.ត្រៀមការពារប្រមុខដឹកនាំ ដែលមកពីប្រទេសផ្សេងៗមកធ្វើទស្សនកិច្ច







នៅប្រទេសកម្ពុជា ។

**ទី៣**.ទប់ស្កាត់ឧបាយកលអមិត្តដែលមានបំណងចង់ផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ដែលក្នុងនាមជាកម្លាំងអាជ្ញាធរមានសមត្ថកិច្ចត្រូវការពារឲ្យបានដាច់ខាតនូវសេចក្តីសុខ និងសន្តិភាពរបស់ប្រជាពលរដ្ឋ ។

ជាមួយគ្នានោះ គណៈបញ្ជាការឯកភាពខេត្ត ត្រូវមានរបបប្រជុំទៀងទាត់ដើម្បីវិភាគស្ថានភាពការណ៍ និងធ្វើការដោះស្រាយបញ្ហានៅក្នុងមូលដ្ឋាន និងត្រូវត្រៀមកម្លាំងអន្តរាគមន៍ ដើម្បីធ្វើការដោះស្រាយជួយប្រជាពលរដ្ឋបានទាន់ពេលវេលា ។ ជាពិសេសត្រូវជំរុញការអនុវត្តន៍គោលនយោបាយ «**ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព**» ដើម្បីរក្សាសេចក្តីសុខជូនប្រជាពលរដ្ឋក្នុងទូទាំងខេត្ត ព្រមទាំងឱកទំនួលសេវាសាធារណៈ និងលិខិតរដ្ឋបាលផ្សេងៗឲ្យបានឆាប់រហ័ស និងត្រូវបំពេញភារកិច្ចបម្រើប្រជាពលរដ្ឋប្រកបដោយមនសិការវិជ្ជាជីវៈ។

ក្នុងនោះត្រូវយកចិត្តទុកដាក់ជួយអប់រំប្រជាពលរដ្ឋឲ្យចូលរួមទាំងអស់គ្នាទាំងការការពារពិនិត្យ និងអប់រំក្រុមគ្រួសារកូនចៅឲ្យយល់ដឹងពីគ្រោះថ្នាក់ដែលកើតឡើងដោយសារការប្រើប្រាស់គ្រឿងញៀន និងគ្រោះថ្នាក់ចរាចរណ៍ ព្រោះថាគ្រោះថ្នាក់នេះបានបង្កផលប៉ះពាល់ធ្ងន់ធ្ងរណាស់ចំពោះគ្រួសារ និងសង្គមជាតិ ។

លើសពីនេះទៀត ស្នងការខេត្តត្រូវជួយគាំទ្រដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលដែលខ្វះខាតកម្លាំងដោយបញ្ជូនកម្លាំងចុះទៅជួយតាមរយៈបេសកកម្មដែលមានរយៈពេលវែងឬខ្លី និងត្រូវបន្តពង្រឹងការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលប៉ុស្តិ៍ ជាពិសេសនគរបាលប៉ុស្តិ៍ត្រូវកែប្រែឥរិយាបថទន់ភ្លន់ជាមួយប្រជាពលរដ្ឋ ប៉ុន្តែម៉ឺងម៉ាត់ចំពោះភារកិច្ច ។

គួរបញ្ជាក់ដែរថា: ក្នុងឱកាសនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ ក៏បាននាំយកអំណោយចែកជូនដល់អតីតយុទ្ធជនចំនួន ៤៣០នាក់ ក្នុងម្នាក់ៗទទួលបានថវិកា ២០ម៉ឺនរៀល អង្ករ៥០គីឡូក្រាម ទឹកត្រី ១កេស មី ១កេស ត្រីខ ១ឡូតិ៍ ទឹកដោះគោឆៅ ១ឡូតិ៍ និងនិវត្តន៍ជនដែលជាជនពិការចំនួន ៥នាក់ ក្នុងម្នាក់ៗទទួលបានប្រាក់ ៤០ម៉ឺនរៀល និងបានផ្តល់ថវិកាជូនដល់ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ចំនួន ១០លានរៀល បញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករងខេត្ត ចំនួន ៣លានរៀល បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត ចំនួន ៣លានរៀល និងឯកឧត្តម បណ្ឌិត រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានឧបត្ថម្ភដល់ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ចំនួន ៤០លានរៀល ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# កិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ ពិភាក្សា
## ដើម្បីការពារបង្គោលព្រំដែន នៅតាមបណ្តោយ





នាព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ ពិភាក្សា និងផ្តល់យោបល់ លើការស្តាបនាច្រាំងទន្លេ ដើម្បីការពារបង្គោលព្រំដែននៅតាមបណ្តោយព្រំដែនប្រទេសកម្ពុជា-វៀតណាម នៅក្នុងទឹកដីខេត្តកណ្តាល ដំណាក់កាលទី២ ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរ៉ែ និងថាមពល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកដ្ឋានជាតិទន្លេសាប គណៈកម្មាធិការទន្លេមេគង្គ អគ្គស្នងការដ្ឋាននគរបាលជាតិ និងរដ្ឋបាលខេត្តកណ្តាល ព្រមទាំងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀត ។



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# និងផ្តល់យោបល់លើការស្ថាបនាច្រាំងទន្លេ ព្រំដែន ប្រទេសកម្ពុជា-វៀតណាម



ឯកឧត្តម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានមានប្រសាសន៍បញ្ជាក់ថា៖ កិច្ចប្រជុំនាពេលនេះជាកិច្ចប្រជុំលើកទី៧ ដើម្បីជជែកពិភាក្សាលើវឌ្ឍនភាពចំពោះផែនការលើការសាងសង់សំណង់រឹងរក្សាស្ថេរភាពច្រាំងទន្លេ នៅតាមបណ្តោយព្រំដែនប្រទេសកម្ពុជា-វៀតណាម នៅក្នុងទឹកដីខេត្តកណ្តាល ដំណាក់កាលទី២ ស្ថិតក្នុងភូមិ ព្រែកផ្ទៃ ឃុំព្រែកផ្ទៃ ស្រុកកោះធំ ។ កិច្ចប្រជុំពេលនេះមានគោលបំណងធំៗ**ចំនួន៣** គឺ**ទី១**-ពិនិត្យវឌ្ឍនភាពច្រាំងទន្លេ ដើម្បីការពារបង្គោលព្រំដែនស្ថិតក្នុងភូមិព្រែកផ្ទៃ ឃុំព្រែកផ្ទៃ ស្រុកកោះធំ **ទី២**-ជជែកពិភាក្សាការត្រៀមលក្ខណៈនៅក្នុងការជួបជាមួយក្រុមការងារថ្នាក់ជាតិរបស់ភាគីវៀតណាម និងជាមួយក្រុមការងារអន្តរក្រសួង និង**ទី៣**-ពិនិត្យលើបញ្ហាប្រឈម និងសំណូមពរ ពិសេសលើការងារបច្ចេកទេសលើការសាងសង់សំណង់ការពារច្រាំងទន្លេ ។

សូមបញ្ជាក់ថា៖ ការសាងសង់ទប់ច្រាំងទន្លេបាសាក់ នៅស្រុកកោះធំ ជាប់ព្រំដែនប្រទេសវៀតណាម មានប្រវែងប្រមាណជាង១៧០០ម៉ែត្រ ដោយមាន ២ដំណាក់កាល គឺដំណាក់កាលទី១ សាងសង់ច្រាំងការពារបណ្តោះអាសន្នប្រវែង ១៥០ម៉ែត្រ ដោយប្រើវិធីសាស្ត្របូមខ្សាច់ច្រកបាវ ជីអូ (Geo Bag) ទ្រាប់ការពារជើងក្រោមមាត់ច្រាំងទន្លេ រហូតដល់ផ្នែកខាងលើ ដើម្បីការពារក្នុងការបញ្ចៀស និងកាត់បន្ថយចរន្តទឹកផ្នែកខាងក្រោមបាតទន្លេ មកបុកស៊ីតាមមាត់ច្រាំងទន្លេ និងដំណាក់កាលទី២ មានប្រវែង ១,១៤០ ម៉ែត្រ ៕



**៣កុំ ៖** -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# កិច្ចប្រជុំពិភាក្សា និងផ្សព្វផ្សាយស្តីពី « យុទ្ធសាស្ត្រនយោបាយព័ត៌មាន »







នារសៀលថ្ងៃទី១៧ ខែមករា ឆ្នាំ ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបិទកិច្ចប្រជុំពិភាក្សា និងផ្សព្វផ្សាយស្តីពី « **យុទ្ធសាស្ត្រនយោបាយព័ត៌មាន** » ដែលរៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ ។

អញ្ជើញមានប្រសាសន៍ក្នុងពិធីបិទកិច្ចប្រជុំនេះ **សម្តេចក្រឡាហោម** បានបញ្ជាក់ថា៖ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយឈ្នះ-ឈ្នះ នាំមកនូវសន្តិភាព ស្ថិរភាពនយោបាយ ឯកភាពជាតិ ការ



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



អភិវឌ្ឍន៍លើគ្រប់វិស័យ និងអភិបាលកិច្ចល្អ ។ បន្ថែមលើនេះទៀតរាជរដ្ឋាភិបាលក៏បានបង្កើត និងអនុវត្តគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់លើគ្រប់វិស័យ ពិសេសការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចឱ្យស្របតាមយុទ្ធសាស្ត្រចតុកោណ ដើម្បីថែរក្សាឱ្យបាននូវសន្តិភាព ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឱ្យមានភាពរុងរឿងសម្បូរសប្បាយ ។

**សម្តេចក្រឡាហោម** បានបញ្ជាក់ជូនអង្គពិធីអំពីសវតា និងបច្ចុប្បន្នភាពនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាថា: ឆ្លងកាត់ដំណាក់កាលជាច្រើនមកទល់បច្ចុប្បន្នកម្ពុជា បានដើរដល់របត់មួយថ្មីនៃការធ្វើកំណែទម្រង់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិធ្វើឱ្យរាជរដ្ឋាភិបាលទទួលបាននូវសមិទ្ធផលដ៏ធំធេងជាប្រវត្តិសាស្ត្រ តាមរយ:ការធ្វើប្រតិភូកម្មអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។



កំណែទម្រង់នេះ គឺមានគោលបំណងលើកកម្ពស់ការផ្តល់សេវាសាធារណ:ឱ្យទៅដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ក៏ដូចជាជំរុញឱ្យប្រជាពលរដ្ឋចូលរួមធ្វើការអភិវឌ្ឍមូលដ្ឋានដែលខ្លួនរស់នៅប្រកបដោយការទទួលខុសត្រូវតម្លាភាព គណនេយ្យភាពជាមួយរដ្ឋបាលមូលដ្ឋានរបស់ខ្លួន ។

មានប្រសាសន៍ពាក់ព័ន្ធផលវិស័យព័ត៌មាន **សម្តេចក្រឡាហោម** បានបញ្ជាក់បន្តថា: វិស័យនេះ ត្រូវបានចាត់ទុកជាវិស័យ

៤៨







៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន
## អនុញ្ញាតឲ្យទីប្រឹក្សាទំនាក់ទំនងកិច្ចការនគរបាល នៃស្ថានទូតចិន ប្រចាំកម្ពុជាចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ





នៅអគ្គស្នងការដ្ឋាននគរបាលជាតិ កាលពីព្រឹកថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៣ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ បានអនុញ្ញាតឱ្យ លោក **លី ស៊ាងមីង** (LI XIANG MING) ទីប្រឹក្សាទំនាក់ទំនងកិច្ចការនគរបាលនៃស្ថានឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ។

ក្នុងជំនួបពិភាក្សាការងារនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានលើកឡើងអំពីសមិទ្ធផលសំខាន់ៗដែលទទួលបាន តាមរយៈកិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិកម្ពុជា និងនគរបាលជាតិចិន និងភាពរីកចម្រើនរបស់នគរបាលជាតិកម្ពុជា ក្នុងកិច្ច



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល





ប្រតិបត្តិការរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈក្នុងព្រឹត្តិការណ៍ជាតិ-អន្តរជាតិនាពេលកន្លងមក និងជាពិសេសគឺការជួយឧបត្ថម្ភគាំទ្រដល់នគរបាលជាតិកម្ពុជា ទាំងឧបករណ៍ និងមធ្យោបាយសម្ភារៈបម្រើឱ្យកិច្ចប្រតិបត្តិការ ការបណ្តុះបណ្តាលកសាងធនធានមនុស្ស និងការជួយដល់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនិងជំងឺកូវីដ-១៩ ព្រមទាំងកិច្ចសហប្រតិបត្តិការគ្នាដ៏ល្អក្នុងការបង្ក្រាបបទល្មើសបោកអនឡាញ ។

ជាការឆ្លើយតប លោក ទីប្រឹក្សាទំនាក់ទំនងកិច្ចការនគរបាលនៃស្ថានឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា បានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំក្រសួងសន្តិសុខសាធារណចិនជូនចំពោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ និងបានថ្លែងនូវការកោតសរសើរចំពោះនគរបាលជាតិកម្ពុជា ដែលបានអនុវត្តផែនការការពារក្នុងព្រឹត្តិការណ៍សំខាន់ៗ ដូចជាកិច្ចការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ កិច្ចប្រជុំកំពូលអាស៊ាន លើកទី៤០-៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ដោយរក្សាបាននូវសុវត្ថិភាពទាំងស្រុងជូនគ្រប់គណៈប្រតិភូចូលរួម ។

ជាមួយគ្នានោះផងដែរ ភាគីចិនក៏បានសន្យាជួយគាំទ្រនគរបាលជាតិកម្ពុជាក្នុងកិច្ចការថែរក្សាសន្តិសុខ សុវត្ថិភាពសង្គមជាពិសេសកិច្ចការការពារព្រឹត្តិការណ៍ធំៗដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ ដូចជាការប្រកួតកីឡា SEA GAMES លើកទី៣២ និងកីឡាជនពិការ ASEAN PARA GAMES លើកទី១២ ឆ្នាំ២០២៣ ការបោះឆ្នោតជាតិ ព្រមទាំងជំរុញការសាងសង់ទីបញ្ជាការអគ្គស្នងការដ្ឋាននគរបាលជាតិ ឱ្យបានចាប់ផ្តើមបើកការដ្ឋាននៅពេលឆាប់ៗខាងមុខនេះ ។

លើសពីនេះទៀតភាគីចិន ក៏បានឯកភាពក្នុងការបណ្តុះបណ្តាលគ្រូបង្គោលរយៈពេលវែង លើការងារជំនាញបច្ចេកទេសវិទ្យាសាស្ត្រកោសល្យវិច្ច័យថ្មីទំនើប និងជំនាញប្រឆាំងបទល្មើសបច្ចេកវិទ្យា ដោយធ្វើការបញ្ជូនគ្រូបង្គោលទៅបណ្តុះបណ្តាលនៅប្រទេសចិន និងត្រឡប់មកបណ្តុះបណ្តាលដល់នគរបាលនៅប្រទេសកម្ពុជាវិញ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# ប្រជុំផ្សព្វផ្សាយអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានសម្រាប់គាំទ្រការអនុវត្ត គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព



ឯកឧត្តម **ប្រាក់ សំអឿន** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានធ្វើរបាយការណ៍ជូន **សម្តេចក្រឡាហោម** និងអង្គពិធីអំពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយចាស់ គឺគោលនយោបាយ«**ភូមិ-ឃុំ មានសុវត្ថិភាព**» ក្នុងរយៈពេល១០ឆ្នាំកន្លងមក និងបានរាយការណ៍អំពីការរៀបចំគោលនយោបាយ«**ភូមិ-ឃុំ- សង្កាត់ មានសុវត្ថិភាព**



សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន សម្រាប់គាំទ្រការអនុវត្តគោលនយោបាយ « **ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព** » ប្រារព្ធនៅសណ្ឋាគារ **សុខាភ្នំពេញ** កាលពីព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣កន្លងមកនេះ។



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

ដែលមានលក្ខណៈសម្បត្តិ ៧ចំណុច ព្រមទាំងការរៀបចំបង្កើតលេខាធិការដ្ឋាន ហៅកាត់ថា **គ.ភ.ឃ.ស** ។

ក្នុងឱកាសនោះដែរ ឯកឧត្តម **យន់ ឈុន្នី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋានគោលនយោបាយ «**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**» បានរាយការណ៍ជូន **សម្តេចក្រឡាហោម** និងអង្គពិធីអំពីវឌ្ឍនភាព ជំហានដំបូងនៃបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួមអនុវត្តគោលនយោបាយ «**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**» ក្នុងឆ្នាំ ២០២២ ។

អញ្ជើញមានប្រសាសន៍ នាឱកាសនោះ **សម្តេចក្រឡាហោម** ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងមហាផ្ទៃ បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រសួង-ស្ថាប័ននានា រដ្ឋបាលថ្នាក់ក្រោមជាតិកងកម្លាំងមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធនានា ព្រមទាំងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ដែលបានគាំទ្រ និងចូលរួមអនុវត្តគោលនយោបាយ«**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**» ដែលសម្រេចដាក់ចេញដោយរាជរដ្ឋាភិបាល និងទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ។



ឯកឧត្តម ប្រាក់ សំអឿន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ





**សម្តេចក្រឡាហោម** បានមានប្រសាសន៍រំលឹក ជូនអង្គពិធីជ្រាបថា៖ យោងអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥ ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជា កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ **សម្តេចតេជោ** បានកំណត់យកគោលការណ៍កសាង«**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**» ដើម្បីជំរុញ និងលើកកម្ពស់ចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ នៅគ្រប់ពេល និងគ្រប់ច្រកល្ហកនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃ បានស្នើរាជរដ្ឋាភិបាលពិនិត្យ សម្រេចដំឡើងកម្រិតគោលនយោបាយ«**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**» ទៅជាគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីពង្រីកវិសាលភាពពីការទទួលខុសត្រូវអនុវត្តតែក្រសួងមហាផ្ទៃ ទៅជាគោលនយោបាយមួយដែលមានការទទួលខុសត្រូវ និងការចូលរួមអនុវត្តពីក្រសួង-ស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាល ហើយផ្អែកលើមូលដ្ឋាននេះ លក្ខណៈសម្បត្តិនៃគោលនយោបាយ «**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**» ដែលធ្លាប់តែគ្របដណ្តប់លើការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក៏ត្រូវបានពង្រីក**វិសាលភាពគ្របដណ្តប់លើវិស័យផ្សេងៗទៀត ហើយបានកំណត់នូវលក្ខណៈសម្បត្តិចំនួន ៧** ។

លក្ខណៈសម្បត្តិទាំង**៧**នោះ រួមមាន **ទី១**- ផ្តល់សេវាសាធារណៈ ជាពិសេស

៣៣



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



តមកពីទំព័រ ៣២

**ប្រជុំផ្សព្វផ្សាយអំពីការរៀបចំ និងការ ...**



សេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត ។ **ទី២**-គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ។ **ទី៣**-មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។ **ទី៤**- គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង ។ **ទី៥**- ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព ។ **ទី៦**-មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ ។ និង**ទី៧**- ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ ប្រកបដោយប្រសិទ្ធភាព ។

**សម្តេចក្រឡាហោម** បានចាត់ទុកការពង្រីកវិសាលភាព និងលើកកម្រិតគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ក៏ធ្វើឡើងក្នុងគោលបំណងដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណ និងជំរុញការអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេសកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ដើម្បីបង្កភាពអនុគ្រោះដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅមូលដ្ឋាន សំដៅរួមចំណែកជាមួយរាជរដ្ឋាភិបាលប្រែក្លាយកម្ពុជា ឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលកម្រិតខ្ពស់ក្នុងឆ្នាំ២០៥០ ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍បន្តថា៖ ដើម្បីជំរុញសម្រេចបានវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយនេះក្រសួង-ស្ថាប័ននានា ដែលមានសមត្ថកិច្ចពាក់ព័ន្ធការផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលដែលជាលក្ខណៈសម្បត្តិទី១ ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនូវចលនាប្រឡងប្រណាំងលើការផ្តល់សេវាសាធារណៈដែលស្ថិតក្រោមសមត្ថកិច្ចទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ននីមួយៗ ខណៈក្រសួងយុត្តិធម៌ដឹកនាំចលនាប្រឡងប្រណាំងពាក់ព័ន្ធការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការដែលជាលក្ខណៈសម្បត្តិទី៥ ។ រីឯក្រសួងបរិស្ថាននឹងដឹកនាំចលនាប្រឡងប្រណាំងពាក់ព័ន្ធនឹងអនាម័យ សោភ័ណភាពបរិស្ថាន ដែលជាលក្ខណៈសម្បត្តិទី៦ ខណៈក្រសួងសុខាភិបាល និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដឹកនាំ



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល





ចលនាប្រឡងប្រណាំងពាក់ព័ន្ធនឹងការឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ ដែលជាលក្ខណសម្បត្តិទី៧ ហើយលេខាធិការដ្ឋាននឹងត្រូវបំពេញតួនាទីក្នុងការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្តគោលនយោបាយខាងលើនេះឱ្យទទួលបានជោគជ័យ ។

**សម្តេចក្រឡាហោម** ក៏បានថ្លែងនូវអំណរគុណដល់អង្គការ **យូនីសេហ្វ** ដែលតែងតែផ្តល់ការឧបត្ថម្ភគាំទ្រទាំងធនធានថវិកា និងបច្ចេកទេស ក្នុងការចូលរួមសម្រេចបាននូវទិសដៅកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់ជីវភាពសុខុមាលភាពរបស់ប្រជាជនកម្ពុជា ។

គួរបញ្ជាក់ថា៖ លេខាធិការដ្ឋាន **គ.ភ.ឃ.ស** មានតួនាទីភារកិច្ច សហការរៀបចំផែនការយុទ្ធសាស្ត្រ ស្តីពីការអនុវត្តគោលនយោបាយ«**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**» រៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់លេខាធិការដ្ឋាន ស្តីពីការសហការសម្របសម្រួលការតាមដានការត្រួតពិនិត្យ និងការជាស់តឿនក្នុងការអនុវត្តគោលនយោបាយ សហការ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរដ្ឋបាលថ្នាក់ក្រោមជាតិ និងគណៈបញ្ជាការឯកភាពគ្រប់ថ្នាក់ក្នុងការអនុវត្តគោលនយោបាយ សហការ និងផ្តល់អនុសាសន៍ក្នុងការអនុវត្តលក្ខណៈសម្បត្តិនៃគោលនយោបាយ «**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**» ។

លេខាធិការដ្ឋាននេះ ក៏មានតួនាទីសហការដឹកនាំ និងផ្តល់អនុសាសន៍ក្នុងការអនុវត្តចលនាប្រឡងប្រណាំងអំពីការអនុវត្តគោលនយោបាយកៀរគរការចូលរួម និងការគាំទ្រពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានា ក្នុងការអនុវត្តគោលនយោបាយ ផ្សព្វផ្សាយគោលនយោបាយ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំពាក់ព័ន្ធគោលនយោបាយ តាមដានត្រួតពិនិត្យ វាយតម្លៃការអនុវត្តគោលនយោបាយ បូកសរុប និងរៀបចំរបាយការណ៍ ស្តីពីការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ជូនក្រសួងមហាផ្ទៃ ដើម្បីរាយការណ៍ជូនទៅប្រមុខរាជរដ្ឋាភិបាលបំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ៕



**៣កុំ ៖** -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ ទទួលជួបពិភាក្សា ការងារជាមួយគណៈប្រតិភូខុទ្ទកាល័យក្រសួងសន្តិសុខសាធារណៈឡាវ

នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ បានទទួលជួបពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ការងារជាមួយគណៈប្រតិភូខុទ្ទកាល័យនៃក្រសួងសន្តិសុខសាធារណៈឡាវ ដែលដឹកនាំដោយ ឯកឧត្តម ឧត្តមសេនីយ៍ទោ **ស៊ុមវ៉ាន់ សាយឡុនហ្វា** នាយកខុទ្ទកាល័យនៃក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។





ក្នុងជំនួបនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការបានមានប្រសាសន៍បញ្ជាក់ថា៖ ផ្អែកលើការផ្លាស់ប្តូរបទពិសោធន៍ការងារនេះដែរ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ បាន



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល









សម្តែងនូវការកត់សម្គាល់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ ក្នុងរយៈពេលជាង ១ឆ្នាំចុងក្រោយនេះឃើញថាប្រមុខរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ បានជួបពិភាក្សាការងារជាបន្តបន្ទាប់ ទាំងក្នុងក្របខណ្ឌទ្វេភាគី និងអាស៊ានដែលបានជំរុញ និងលើកកម្ពស់ចំណងមិត្តភាពដ៏រឹងមាំ និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ ។ ទន្ទឹមនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ ក៏បានសម្តែងនូវការអបអរសាទរផងដែរ ចំពោះការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដែលរដ្ឋាភិបាលនៃប្រទេសទាំងពីរតែងជួយគាំទ្រគ្នាទៅវិញទៅមកដោយឈរលើស្មារតីមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការល្អ ដើម្បីបុព្វហេតុរួមនៃសុខុមាលភាពរបស់ប្រជាជននៃប្រទេសទាំងពីរ ។

មានមតិឆ្លើយតបវិញ ឯកឧត្តម ឧត្តមសេនីយ៍ទោ នាយកខុទ្ទកាល័យនៃក្រសួងសន្តិសុខសាធារណៈឡាវ បានថ្លែងអំណរគុណចំពោះ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ ដែលបានឆ្លៀតពេលវេលាដ៏មមាញឹកអនុញ្ញាតឱ្យ ឯកឧត្តម និងគណៈប្រតិភូចូលជួបពិភាក្សាការងារ និងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ដើម្បីរឹតចំណងមិត្តភាព និងបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក្រសួងទាំងពីរ និងខុទ្ទកាល័យទាំងពីរ នាពេលអនាគតក្នុងតួនាទីស្នូលជាសេនាធិការជូនថ្នាក់ដឹកនាំក្រសួងនៃប្រទេសទាំងពីរ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# បិទវគ្គបណ្តុះបណ្តាល ស្តីពី

## តួនាទីភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល ការងារនគរបាល និងសហគមន៍ និងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព



រសៀលថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២៣កន្លងមកនេះ ឧត្តមសេនីយ៍ឯក **ឆាយ គឹមខឿន** អគ្គស្នងការរងនគរបាលជាតិតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ បានអញ្ជើញជាអធិបតីក្នុងពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីតួនាទីភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលការងារនគរបាល និងសហគមន៍ និងអនុវត្តគោលនយោបាយភូមិ-ឃុំសង្កាត់មានសុវត្ថិភាព នៅស្នងការដ្ឋាននគរបាលខេត្តកណ្តាល ។



ឧត្តមសេនីយ៍ទោ ឈឿន សុចិត្ត ស្នងការនគរបាលខេត្តកណ្តាល

ឧត្តមសេនីយ៍ទោ **ឈឿន សុចិត្ត** ស្នងការនគរបាលខេត្តកណ្តាលបាន បញ្ជាក់ថា៖ ដោយមានការយកចិត្តទុកដាក់ពីសំណាក់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ពិសេសដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និងការជំរុញលើកទឹកចិត្តគាំទ្រយ៉ាងពេញទំហឹងពី ឧត្តមសេនីយ៍ឯក **ឆាយ គឹមខឿន** អគ្គស្នងការរងនគរបាលជាតិ ទទួលបន្ទុកសេនាធិការ ទើបស្នងការដ្ឋាននគរបាលខេត្តកណ្តាល សហការជាមួយនាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល បានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីតួនាទីភារកិច្ចប៉ុស្តិ៍នគរបាល





៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល













រដ្ឋបាល ការងាររដ្ឋបាល សហគមន៍ និងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ជូនដល់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលដែលពុំទាន់ឆ្លងវគ្គនៅតាមបណ្តាអធិការដ្ឋាននគរបាលក្រុង-ស្រុកទាំង១១ រយៈពេល០៥ថ្ងៃ ដែលមានសិក្ខាកាម សរុប ១២០នាក់ ស្រី២៧នាក់ ។

ឧត្តមសេនីយ៍ឯក អគ្គស្នងការរងនគរបាលជាតិ បានមានប្រសាសន៍សំដែងនូវការកោតសរសើរចំពោះនាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល និងស្នងការដ្ឋាននគរបាលខេត្តកណ្តាល ដែលបានសហការគ្នាល្អក្នុងការរៀបចំបង្កើតឲ្យមានវគ្គបណ្តុះបណ្តាលដ៏មានសារសំខាន់នេះឡើង ហើយក៏ជាវគ្គបណ្តុះបណ្តាលគំរូមួយសម្រាប់ការងារលើកស្ទួយ ពង្រឹងសមត្ថភាពមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលនៅទូទាំងប្រទេស ។ មិនតែប៉ុណ្ណោះ ក្រោយពីបញ្ចប់វគ្គនេះទៅនៅតាមប៉ុស្តិ៍នគរបាលរដ្ឋបាលរបស់យើងនឹងមានមន្ត្រីដែលមានសមត្ថភាពជួយបម្រើសេវាប្រជាពលរដ្ឋកាន់តែសកម្មថែមទៀត ។

ជាមួយគ្នានោះ ឧត្តមសេនីយ៍ឯក អគ្គស្នងការរងក៏បានស្នើឲ្យប៉ុស្តិ៍នគរបាលរដ្ឋបាលទាំងអស់ត្រូវយកចិត្តទុកដាក់ក្រប់គ្រង ដឹកនាំប្រជាការពារ ព្រោះថាប្រជាការពារមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ក៏ពិតមែន តែក៏ជាកម្លាំងជំនួយដ៏សំខាន់ជួយដល់សមត្ថកិច្ចនូវរាល់កិច្ចការងាររបស់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលផងដែរ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ក្រសួងមហាផ្ទៃ ពិនិត្យពិភាក្សា ស្តីពី គម្រោងសេវាប្រព័ន្ធថែទាំ និងប្រព័ន្ធសុវត្ថិភាព សម្រាប់អគារទីស្តីការថ្មី





នាព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣ កន្លងមកនេះ អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ បើកកិច្ចប្រជុំពិនិត្យពិភាក្សាស្តីពីគម្រោងសេវាថែទាំប្រព័ន្ធទឹក ភ្លើង ម៉ាស៊ីនត្រជាក់ ប្រព័ន្ធសុវត្ថិភាព និងសម្អាត សម្រាប់អគារទីស្តីការថ្មីក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ តក្តិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រុមហ៊ុន ដែលផ្តល់គម្រោងសេវាថែទាំបច្ចេកទេស ជាច្រើនរូប ។

នាឱកាសនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ បានមានប្រសាសន៍បញ្ជាក់អំពីតម្រូវការសេវាកម្មចាំបាច់មួយចំនួនសម្រាប់បំពាក់ក្នុងអគារថ្មីរបស់



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







ក្រសួងមហាផ្ទៃ ដែលឯកឧត្តម នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា៖ ដោយសារតែទំហំអគារថ្មីរបស់ក្រសួងមហាផ្ទៃ មានលក្ខណៈធំ ហើយក្នុងន័យ ដើម្បីធ្វើឲ្យលក្ខណៈសម្បត្តិឱ្យបានគ្រប់គ្រាន់សម្រាប់ធ្វើការថែទាំ ធ្វើយ៉ាងណារក្សាបរិយាកាសបំពេញការងាររបស់ថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការគ្រប់ថ្នាក់ទាំងអស់នៅអគារទីស្តីការថ្មី ក្រសួងមហាផ្ទៃមានភាពល្អប្រសើរ ។

ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ មានប្រសាសន៍បញ្ជាក់បន្ថែមថា៖ កាលពីពេលកន្លងទៅក្រសួងមហាផ្ទៃ បានប្រើប្រាស់មន្ត្រីផ្ទាល់ ដើម្បីធ្វើការសម្អាត និងថែទាំតាមនាយកដ្ឋានរៀងៗខ្លួន ដោយឡែកការងារពាក់ព័ន្ធម៉ាស៊ីនត្រជាក់ ប្រព័ន្ធភ្លើង និងសម្ភារៈបច្ចេកទេសនានា មានច្រើនដែលក្រសួងត្រូវការអ្នកបច្ចេកទេសជាប្រចាំ ដើម្បីធ្វើការត្រួតពិនិត្យ និងថែទាំ ដូច្នេះកិច្ចប្រជុំនាថ្ងៃនេះគឺធ្វើឡើងដើម្បីស្តាប់បទបង្ហាញរបស់ក្រុមហ៊ុនបច្ចេកទេសសម្រាប់ជាមូលដ្ឋានពិចារណាស្វែងរកចំណុចឯកភាពគ្នា ។

ជាមួយគ្នានោះ តំណាងក្រុមហ៊ុនទទួលបន្ទុក ដែលផ្តល់គម្រោងសេវាថែទាំប្រព័ន្ធទឹក ភ្លើង ម៉ាស៊ីនត្រជាក់ ប្រព័ន្ធសុវត្ថិភាព និងសម្អាត សម្រាប់អគារទីស្តីការថ្មីក្រសួងមហាផ្ទៃ បានធ្វើបទបង្ហាញលម្អិតស្តីពីប្រព័ន្ធបច្ចេកទេស និងគម្រោងសេវាកម្មរបស់ក្រុមហ៊ុននីមួយៗជូន ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ និងអង្គប្រជុំបានជ្រាប ។

ក្រោយពីបានស្តាប់បទបង្ហាញរបស់តំណាងក្រុមហ៊ុនរួចមក ឯកឧត្តម នាយឧត្តមសេនីយ៍ បានណែនាំឱ្យតំណាងក្រុមហ៊ុន សិក្សារៀបចំនូវឯកសារពាក់ព័ន្ធឱ្យបានលម្អិតបន្ថែមទៀតលើសេវាកម្មរបស់ខ្លួនឡើងវិញ ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យ និងពិភាក្សាសម្រេច ដើម្បីដាក់ជូនគណៈកម្មការសាងសង់អគារទីស្តីការថ្មីរបស់ក្រសួងមហាផ្ទៃ ក៏ដូចជាថ្នាក់ដឹកនាំពិនិត្យ និងសម្រេចជាផ្លូវការ ។

គួរបញ្ជាក់ផងដែរថា៖ ក្រសួងមហាផ្ទៃបានរៀបចំពិធីបញ្ចុះបឋមសិលាសាងសង់អគារថ្មីរបស់ទីស្តីការក្រសួងមហាផ្ទៃ កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ និងគ្រោងបញ្ចប់ នាចុងខែមិថុនា ឆ្នាំ២០២៣ ខាងមុខ ។ ដូច្នេះគិតត្រឹមដំណាច់ខែកុម្ភៈ ឆ្នាំ២០២៣នេះ ក្រុមហ៊ុន **គ៊ីម មិច** ដែលទទួលបានសិទ្ធិក្នុងការសាងសង់ នៅសល់ពេលវេលាប្រមាណ៤ខែទៀត ប៉ុណ្ណោះដើម្បីបញ្ចប់ការងាររបស់ខ្លួន ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



តមកពីទំព័រ ០៨

## នាយករដ្ឋមន្ត្រីស្តីទី អញ្ជើញដឹកនាំកិច្ចប្រជុំ ...

ជាសមាជិកប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ាន ដូច្នេះការប្តេជ្ញាចិត្ត របស់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធលើការងាររក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ សាធារណៈពិតជាមានសារសំខាន់ណាស់ ក្នុងការការពារសុវត្ថិភាពទាំងនៅកន្លែងប្រកួតនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត។

នាឱកាសនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងប្រធានគណៈកម្មការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៃគណៈកម្មការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ (CAMSOC) បានធ្វើរបាយការណ៍ជូន**សម្តេចក្រឡាហោម នាយករដ្ឋមន្ត្រីស្តីទី** និងអង្គប្រជុំស្តាប់អំពីផែនការលំអិតដាក់ស្តែងអំពីការពារសន្តិសុខ និងសណ្តាប់ធ្នាប់សម្រាប់ការប្រកួតកីឡាស៊ីហ្គេមនេះថា៖ ផែនការនេះបានកសាងឡើងដោយផ្អែកលើមូលដ្ឋាន ៣ចំណុច រួមមាន ការវាយតម្លៃពីសភាពការណ៍ក្នុង និងក្រៅប្រទេស ការអនុលោមតាមកម្មវិធីសន្តិសុខ និងការសិក្សាផ្ទាល់អំពីភូមិសាស្ត្រ ប្រជាសាស្ត្រ និងស្ថានភាពជាក់ស្តែង ដើម្បីការពារឱ្យបានដាច់ខាតនូវសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីបង្កើនកិត្យានុភាពកម្ពុជា ។

សូមបញ្ជាក់ថា៖ ព្រឹត្តិការណ៍ស៊ីហ្គេម លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ដែលព្រះរាជាណាចក្រកម្ពុជាធ្វើជាម្ចាស់ផ្ទះពេលនេះនឹងប្រារព្ធធ្វើឡើង ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣។ ព្រឹត្តិការណ៍នេះមានការចូលរួមពីប្រតិភូកីឡាមកពី ១២ប្រទេស រួមមានប្រទេសសមាជិកអាស៊ានបូកទាំងទីម័រឡេស្តេ និងប្រទេសអូស្ត្រាលី ដែលបានបញ្ជូនប្រតិភូកីឡាបាល់ទាត់ ៕


ព្យាបាល និងដាក់ធ្មេញមិនគិតថ្លៃ

**មន្ទីរពេទ្យ ១៦ ឧសភា** របស់នាយកដ្ឋានសុខាភិបាល អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ដែលមានទីតាំងនៅភូមិតាងៅក្រោម សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

សូមជូនដំណឹងដល់កងកម្លាំងនគរបាលជាតិ និងប្រជាជនទូទៅទាំងអស់ឱ្យបានជ្រាបថា : **មន្ទីរពេទ្យ ១៦ ឧសភា** បានរៀបចំព្យាបាលធ្មេញដោយឥតគិតថ្លៃ ។

**ក្នុងនោះមាន :**
- **ដកធ្មេញ**
- **សំអាតធ្មេញ**
- **ប៉ះធ្មេញ**
- **ព្យាបាលធ្មេញ**

**ចំពោះ**មន្ត្រីនគរបាលជាតិគ្រប់អង្គភាពទូទាំងប្រទេសដែលចង់មកទទួលសេវាដាក់ធ្មេញមិនមានគិតថ្លៃអ្វីទាំងអស់ត្រូវមាន ***(អត្តសញ្ញាណប័ណ្ណនគរបាល)*** ។

*** បញ្ជាក់: ដោយឡែកប្រជាជនទូទៅមានតម្លៃដូចខាងក្រោម :**

*-តម្លៃធ្មេញធម្មតា ១គ្រាប់ ១០$ (តម្លៃទីផ្សារខាងក្រៅ ១គ្រាប់ ៣០$*

*-តម្លៃធ្មេញ Ceramic ១គ្រាប់ ៣០$ (តម្លៃទីផ្សារខាងក្រៅ១គ្រាប់ ៨០$*

*ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ : 092 645 171, 015 75 79 79*





វេជ្ជបណ្ឌិត ញ៉ែម សុខន

បន្ទប់ពិនិត្យ-ពិគ្រោះនិងព្យាបាលជម្ងឺទូទៅ

- ឯកទេសផ្នែកជំងឺទូទៅ និងរូបភាពវេជ្ជសាស្ត្រ

មានពិនិត្យអេកូសាស្ត្រពណ៌ផ្នែក :
- សរីរាង្គក្នុងពោះមាន: ថ្លើម, ប្រមាត់, លំពែង, បំពង់បង្ហូរទឹកប្រមាត់, តម្រងនោម។
- សរីរាង្គរោគស្ត្រី: ស្បូន, ដៃស្បូន, និងពិនិត្យផ្ទៃពោះ

សរីរាង្គក្រពេញទារ៉ូអ៊ីដ : ពកក

- មានបទពិសោធន៍ក្នុងការងារពិនិត្យ និងព្យាបាលជំងឺរយៈពេល ២០ឆ្នាំ ។

បញ្ចុះតម្លៃ ១០% សម្រាប់មន្ត្រីនគរបាលជាតិ





អាសយដ្ឋានផ្ទះលេខ១៣៨អឺសូន្យ ផ្លូវ២១៥ (នេរុហ៍) សង្កាត់វាលវង់ ខណ្ឌ៧ មករា រាជធានីភ្នំពេញ (ខាងត្បូងស្តុបផ្សារដេប៉ូចម្ងាយ៥០ម៉ែត្រ)

ទូរស័ព្ទ: 097 2666 215 / 012 848 917

កម្មការអន្តរក្រសួងរួចមក **សម្តេចក្រឡាហោម** បានអញ្ជើញផ្តល់គោលការណ៍ណែនាំនិងជំរុញលើកទឹកចិត្តឱ្យក្រសួង-ស្ថាប័ន គណៈបញ្ជាការឯកភាពរាជធានី-ខេត្តនិងអាជ្ញាធរពាក់ព័ន្ធទាំងអស់សហការរួមគ្នាអនុវត្តផែនការសកម្មភាពនេះប្រកបដោយការទទួលខុសត្រូវខ្ពស់ និងអំពាវនាវដល់កម្មករនិយោជិកបរទេស និយោជក







តមកពីទំព័រ ១៤

## សម្តេចក្រឡាហោម អញ្ជើញជាអធិបតី ...

នៃរោងចក្រ សហគ្រាសមូលដ្ឋានអាជីវកម្ម និងអ្នកពាក់ព័ន្ធទាំងអស់ផ្តល់ការគាំទ្រ និងចូលរួមអនុវត្តឱ្យបានត្រឹមត្រូវ ។

**សម្តេចក្រឡាហោម** ក៏បានណែនាំគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ត្រូវដឹកនាំ ណែនាំ សហការ សម្រប សម្រួល ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រង និងចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេសដល់កម្មករនិយោជិកបរទេស និងនិយោជកនៃរោងចក្រសហគ្រាស និងមូលដ្ឋានអាជីវកម្មនានាក្នុងមូលដ្ឋានរាជធានី-ខេត្ត របស់ខ្លួន ហើយតាមដាន ត្រួតពិនិត្យ ដំណើរការអធិការកិច្ចហត្ថពលកម្មបរទេសឱ្យបានម៉ត់ចត់ តាមប្រព័ន្ធគោលការណ៍ និងនីតិវិធីកំណត់ដោយតម្លាភាព គណនេយ្យភាព និងត្រូវធានារក្សាឱ្យបានសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងមិនត្រូវធ្វើឱ្យប៉ះពាល់ឬរំខានដល់ដំណើរការផលិតកម្ម អាជីវកម្មស្របច្បាប់របស់រោងចក្រសហគ្រាស និងមូលដ្ឋាន អាជីវកម្មនានា នោះឡើយ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍បន្ថែមថា ក្នុងពេលចុះធ្វើអធិការកិច្ច ករណីរកឃើញតម្រុយសង្ស័យបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម អាជីវកម្មផ្លូវភេទ ឬបទល្មើសផ្សេងៗទៀត ក្រុមចម្រុះអធិការកិច្ចត្រូវរាយការណ៍ជាបន្ទាន់មកគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និងគណៈកម្មការអន្តរក្រសួងដើម្បីចាត់វិធានការស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។ ជាមួយគ្នានេះ គណៈកម្មការអន្តរក្រសួងត្រូវរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដំណើរការធ្វើរបាយការណ៍ស្ទីមប្រកាសក្នុងដំណាក់កាលទី១ និងការចុះធ្វើអធិការកិច្ចក្នុងដំណាក់កាលទី២ សំដៅដោះស្រាយបញ្ហាប្រឈមដោយប្រជុំដកពិសោធន៍ និងជំរុញការអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**សម្តេចក្រឡាហោម** ក៏បានណែនាំអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អាជ្ញាធរកងកម្លាំងមានសមត្ថកិច្ចគ្រប់ថ្នាក់ ត្រូវពង្រឹងការគ្រប់គ្រងជនបរទេសស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ការ ទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ សំដៅពង្រឹងសន្តិសុខជាតិ និងសុវត្ថិភាពសង្គម ។ ជាពិសេសត្រូវពង្រឹងកិច្ចសហការសម្របសម្រួល ធ្វើសកម្មភាពឱ្យបានព្រមៗគ្នា រវាងយន្តការប្រតិបត្តិការទាំង៣ គឺ**គណៈបញ្ជាការដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រុមការងារបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ និងគណៈកម្មការអន្តរក្រសួងដែលបានប្រកាសផ្សព្វផ្សាយនៅថ្ងៃនេះ** ។

ជាមួយគ្នានោះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា **សម្តេច** បានស្នើស្ថានទូតស្ថានតំណាងប្រទេសនានា នៅកម្ពុជាដែលមានពលរដ្ឋកំពុងស្នាក់នៅ និងធ្វើការនៅកម្ពុជា សូមជួយអប់រំអំពីច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រងហត្ថពលកម្មបរទេស ដើម្បីបង្ការទប់ស្កាត់ការមកធ្វើការខុសច្បាប់ និងស្នើសុំកិច្ចសហប្រតិបត្តិការរួមគ្នាស្រាវជ្រាវ បង្ក្រាបបណ្តាញមេខ្យល់ មេក្លោង សំដៅកាត់ផ្តាច់បណ្តាញប្រព្រឹត្តបទល្មើសឱ្យមានប្រសិទ្ធភាព ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ឧត្តមសេនីយ៍ឯក ស ថេត ទទួលជួបពិភាក្សាការងារ ជាមួយគណៈប្រតិភូនគរបាលភូមិន្ទម៉ាឡេស៊ី



នៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ កន្លងមកនេះ ឧត្តមសេនីយ៍ឯក **ស ថេត** អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ បានអនុញ្ញាតឲ្យគណៈប្រតិភូនគរបាលភូមិន្ទម៉ាឡេស៊ី ដឹកនាំដោយ ឯកឧត្តម **ដាតូស្រី អែបចាលីល ប៊ីនហាសាន់** (Dato Sri Abd Jalil Bin Hassan) ប្រធាននាយកដ្ឋាននគរបាលស៊ើបអង្កេតបទល្មើសឧក្រិដ្ឋ ចូលជួបពិភាក្សាការងារស្តីពីកិច្ចសហប្រតិបត្តិការលើការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរ និងរត់ពន្ធមនុស្សខុសច្បាប់ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម **ដាធុក អែលឌីន ហ៊ូសេនី ម៉ដ ហាហ៊ីម** (Datuk Eldeen Husaini Mohd Hashim ) ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជាផងដែរ ។

ក្នុងជំនួបពិភាក្សានោះឧត្តមសេនីយ៍ឯក អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ បានជម្រាបជូនភ្ញៀវអំពីសភាពការណ៍ទូទៅនៅក្នុងរាជធានីភ្នំពេញ គឺជារួមសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់មានសុខសុវត្ថិភាពនិងស្ថិរភាពល្អ ជាមួយគ្នានោះក៏មានកើតឡើងនូវបទល្មើសព្រហ្មទណ្ឌ គ្រឿងញៀន ល្បែងស៊ីសងតាមអនឡាញខុសច្បាប់មួយចំនួនផងដែរ ប៉ុន្តែបទល្មើសដែលកើតឡើងទាំងនោះភាគច្រើនត្រូវបានកម្លាំងសមត្ថកិច្ចទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលា ។

ទន្ទឹមនេះឧត្តមសេនីយ៍ឯក អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ ក៏បានស្នើសុំកិច្ចសហការពីភាគីនគរបាលភូមិន្ទម៉ាឡេស៊ី



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




រួមមាន៖ ការសហការផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកអំពីមុខសញ្ញាការជួញដូរពលកម្ម ការជួញដូរមនុស្ស គ្រឿងញៀន ភេរវកម្ម ឧក្រិដ្ឋកម្ម ការឆបោក និងការបង្ខាំងមនុស្សខុសច្បាប់ ដើម្បីមានវិធានការណ៍ដោះស្រាយរាល់បទល្មើសទាំងនេះទាន់ពេលវេលា និងស្នើសុំឱ្យជនជាតិម៉ាឡេស៊ី ដែលចូលមកព្រះរាជាណាចក្រកម្ពុជា ពិសេសមកស្នាក់នៅរាជធានីភ្នំពេញត្រូវចុះបញ្ជីតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យជនបរទេស (FPCS) តាមការណែនាំរបស់សមត្ថកិច្ច ។






មានមតិឆ្លើយតបវិញ ឯកឧត្តមប្រធាននាយកដ្ឋាននគរបាលស៊ើបអង្កេតបទល្មើសឧក្រិដ្ឋ ម៉ាឡេស៊ី បានបង្ហាញនូវការព្រួយបារម្ភរបស់ពិភពលោកអំពីបញ្ហាបទល្មើសរត់ពន្ធមនុស្ស និងការជួញដូរមនុស្ស ដោយឡែកសម្រាប់ប្រទេសម៉ាឡេស៊ី គឺបទល្មើសប្រឆាំងការជួញដូរមនុស្សត្រូវបាននាយកដ្ឋានស៊ើបអង្កេតបទល្មើសឧក្រិដ្ឋគឺជាអ្នកទទួលបន្ទុកក្នុងការប្រឆាំងបទល្មើសនេះ។ ទន្ទឹមនេះ ជុំវិញកិច្ចការងារប្រឆាំងការជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាពគឺទាមទារឱ្យមានកិច្ចសហប្រតិបត្តិការពីបណ្ដាប្រទេសនានាជាដៃគូរ ដើម្បីរួមគ្នាតស៊ូលុបបំបាត់ការជួញដូរមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេសការជួយសង្គ្រោះជនរងគ្រោះ និងការផ្ដល់ព័ត៌មានគ្នាទៅវិញទៅមកក្នុងការកំណត់មុខសញ្ញាជនល្មើសជាមួយការអនុវត្តវិធានការច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព ។៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




SK Teeth Whitening Powder

ជាប្រភេទម្សៅដុសធ្មេញឲ្យស សម្រាប់អ្នកដែលមិនមានពេលទំនេរច្រើន ។ ហើយក៏អាចប្រើជាមួយឈុត Home Kit សម្រាប់ប្រភេទធ្មេញលឿងខ្លាំងពីកំណើត ។ លក្ខណៈពិសេសរបស់វាគឺមានតួនាទីជួយសំអាតជាតិកំបោរលើធ្មេញបានយ៉ាងល្អ ។ ប្រើរយៈពេល ៧ថ្ងៃ ចាប់ផ្តើមឃើញលទ្ធផល ។




SK Luxury Kit

ជាប្រភេទពន្លឺធ្វើអោយធ្មេញស ដែលមានមុខងារពិសេសៗ ជាច្រើនរួមបញ្ចូលគ្នាក្នុងប្រអប់ Luxury Kit តែមួយ ។ មានវីតាមីនជួយការពារធ្មេញ អញ្ចាញធ្មេញ និងការពារស្រៀវស្រគា។ Luxury Kit Design ឡើងយ៉ាងសាកសមបំផុតសម្រាប់មនុស្សសម័យថ្មី ផ្លែផ្ការជាមួយនិងបច្ចេកវិទ្យាទំនើប និងការវិចខ្ចប់ដ៏ស្រស់ស្អាត។ អាចធ្វើជាការជូរជូនមនុស្សជាទីស្រលាញ់ ។ ប្រើប្រាស់រយៈពេល៧ថ្ងៃឃើញលទ្ធផល។




Set Luxury + Powder

ឈុតពិសេសសំរាប់ធ្មេញលឿងខ្លាំងពីកំណើត

| | |
|---|---|
| -ប្រើបាន ២៤ ដង | -គុណភាពសល្បឿន គុណានិង២ |
| -មានអនាម័យខ្ពស់ ការវិចខ្ចប់ខ្ពស់ | -មានវិតាមីន C ការពារអញ្ចាញ |
| -មាន Florine ការពារធ្មេញពុក | -មាន Potassium nitrate ការពារស្រៀវ រី ស្រគាធ្មេញ |

-ជួយធ្វើអោយធ្មេញភ្លឺរលោង សស្អាត កំចាត់កំនរកំបោរ និងស្នឹបខ្មៅៗ លើធ្មេញប្រើរយៈពេល ៥ថ្ងៃ ចាប់ផ្តើមឃើញធ្វើប្លែក ។




SK Home Kit Teeth Whitening

សម្រាប់ប្រភេទធ្មេញធម្មតាជាប្រភេទពន្លឺធ្វើអោយធ្មេញស ប្រើដោយខ្លួនឯងនៅផ្ទះ ដោយមិនចាំបាច់ចំណាយពេលវេលា Clinic សម្រាប់ប្រភេទធ្មេញលឿងធម្មតា មិនស្រៀវ មិនលឿងពីកំណើត ប្រើប្រាស់រយៈពេល ៧ថ្ងៃ ចាប់ផ្តើមឃើញលទ្ធផល ។




Madamk Menbrane Gel

ជួយផ្តល់សំណើមយ៉ាងល្អដល់ស្បែកមុខ
បំបាត់នូវបញ្ហា
-រមាស់ -ក្រហម -របកស្បែក -រលាក




Madamk Healing Set Membrane Gel Add Oil

ជាប្រភេទឡេលាបថែរក្សា និង បំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺរលោង ការពារមុខជាំ អាចំរុយ ហើយជួយផ្តល់សំណើមដល់ស្បែក និងជួយបំបាត់រាល់បញ្ហារមាស់ក្រហមខ្លាំង របកស្បែករលាក ថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ។ លក្ខណៈពិសេស គឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នកដែលបន្សល់មកពីផលិតផលចាស់ៗ ដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និង ក្រាស់ឡើញវិញ ។




Madamk Healing Set

ជាប្រភេទឡេលាបថែរក្សា និងបំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺមន្តរលោង ការពារមុខជាំ អាចម៍រុយ និងជ្រួញ ហើយថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ម្យ៉ាងទៀតវាអាចជួយអោយស្បែកបាត់ស្តើងសរសៃក្រហមផងដែរ ។ លក្ខណៈពិសេសគឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នក ដែលបន្សល់មកពីផលិតផលចាស់ៗ ដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និងក្រាស់ឡើញវិញ ។

ផ្ទះលេខ 100 ផ្លូវ 164 សង្កាត់អូរឬស្សី ខណ្ឌ7មករា ទូរស័ព្ទ : 017 777 839 / 016 777 839




## Madamk Aromatic Nourishing Face Oil

មានមុខងារ

-ជួយបំបាត់មុខក្រហម

-ជួយបំបាត់មុខស្តើងសរសៃក្រហម

-ជួយស្បែកមានជាតិទឹក ភ្លឺរលោងក្មេងជាងវ័យ ចំពោះអ្នកមានអាយុលើសពី ៣០ឆ្នាំ ឡើងទៅប្រើ Oil នេះរាល់ថ្ងៃវាជួយផ្តល់ជាតិទឹក អោយមុខក្មេងជាងវ័យ និងពន្យាភាពចាស់ផងដែរ។

## Madamk Hair Shampoo & Hair Conditioner

មុខងារ :

-ជួយបណ្តុះសក់

-ជួយព្យាបាលសរសៃសក់ដែលខូចខ្លាំង

-ជួយធ្វើអោយសក់ទន់រលោងក្រអូបនិងជួយអោយសក់រឹងមាំ

-លាងជំរះស្បែកក្បាលបានល្អ បំបាត់អង្គែ និងរមាស់




## Madamk Advance Eye Essence

-ជាសេរ៉ូលាបភ្នែក វាមានតួនាទី២យ៉ាង ទី១ ព្យាបាល ទី២ បញ្ឈោតភ្លាមៗ

-ជួយអោយភ្នែកបាត់ខ្មៅ បាត់ស្លក់ បាត់ជ្រួញ

-លាបភ្លាមឃើញភ្នែកអន់ខ្មៅ អន់ជ្រួញ អន់ស្លក់ភ្លាមៗ ២០-៣០% (លាងទឹកត្រលប់មកធម្មតាវិញ)

-លាបរយៈពេល ៣ខែឡើង ចាប់ផ្តើមឃើញលទ្ធផល

-លាបចូលអស់មិនកក លាបច្រើនយ៉ាងណាក៏មិនកក និងអាចលាបនៅកន្លែងណាដែលមានស្នាមជ្រួញបានផលដែរ។







## Madamk Qwhite Body Lotion

ជាឡេលាបខ្លួនអោយស្បែក ស មន្តរលោង វាមានតួនាទី ៣យ៉ាង :

ទី១ បញ្ឈោតអោយ ស ភ្លាម

ទី២ ធ្វើអោយស្បែក ស ពីខាងក្នុងពិតប្រាកដ

ទី៣ ជួយការពារកំម្តៅថ្ងៃបានយ៉ាងល្អ។

(លាងទឹកត្រលប់មកធម្មតាវិញ)

-លាបចាប់ពី ៣ខែ ឡើងទើបឃើញលទ្ធផល ស្បែកសភ្លឺចេញពីក្នុង

-ស បែបស្បែកមានសុខភាពល្អ

-ជួយការពារកម្តៅថ្ងៃបានយ៉ាងល្អ SPF 25 រយៈពេល ៣ខែឡើងចាប់ផ្តើមឃើញលទ្ធផល




## Madamk Herbal Cream ជា Cream

ផ្សំពីផ្កា ឬសឈើ និងម្សៅគុជខ្យងជួយ :

-បឺតជាតិពុល ជាតិថ្នាំគីមីពីក្រោមស្បែកមុខដែលបន្សល់ពីផលិតផលចាស់

-បំបាត់អាល រឺមុខ

-ជួយផ្ចិតរុនញើស

-ជួយអោយមុខភ្លឺរលោង






## Madamk Healing Specail

ជាប្រភេទឡេលាបថែរក្សា និងបំប៉នស្បែកមុខ វាជួយអោយមុខយើងសភ្លឺរលោង ការពារមុខជាំ អាចម៉ុយ ហើយជួយផ្តល់សំណើមដល់ស្បែក និងជួយបំបាត់អាល រឺ មុនកប់ ជួយផ្ចិតរុញញើស ថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ម្យ៉ាងទៀតវាអាចជួយអោយស្បែកបាត់ស្តើងសរសៃក្រហមបានផងដែរ ។ លក្ខណៈពិសេស គឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នកដែលបន្សល់មកពីផលិតផលចាស់ៗដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និងក្រាស់ឡើងវិញ។

## Madamk Armpit Scrub ជាសាប៊ូដុះពេលងូតទឹក

-ជួយបំបាត់ក្លិនក្លៀកភ្លាមៗក្រោយពេលងូតទឹករួច

-ជួយអោយក្លៀក ស មន្ត បាត់ងំពក មិនមានជាតិថ្នាំពេទ្យដែលប៉ះពាល់ស្បែកក្លៀកទេ។

**ផ្ទះលេខ 100 ផ្លូវ 164 សង្កាត់អូរឫស្សី ខណ្ឌ7មករា ទូរស័ព្ទ : 017 777 839 / 016 777 839**





តមកពីទំព័រ ២០

**សន្និបាត បូកសរុបត្រួតពិនិត្យលទ្ធផល.....**

ការបណ្តុះបណ្តាលឆ្លើយតបទៅនឹងតម្រូវការអង្គភាពប្រើប្រាស់កងកម្លាំងផែនការអភិវឌ្ឍន៍ធនធានមនុស្សរបស់ក្រសួងមហាផ្ទៃ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

អញ្ជើញមានប្រសាសន៍ ក្នុងពិធីបិទសន្និបាតពេលនោះ ឯកឧត្តម សន្តិបណ្ឌិត រដ្ឋលេខាធិការ បានសំដែងនូវការកោតសរសើរចំពោះថ្នាក់ដឹកនាំសាស្ត្រាចារ្យ គ្រូនគរបាលជាតិ និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃបណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងការខិតខំប្រឹងប្រែងបំពេញភារកិច្ចរួមគ្នារស់ពីកម្លាំងកាយចិត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីកសាងស្នាដៃ និងបង្កើតបានសមិទ្ធផលសំខាន់ៗជាច្រើនបន្ថែមទៀតទាំងផ្នែករឹង និងផ្នែកទន់ក្នុងរយៈពេល១ឆ្នាំកន្លងទៅនេះ ទោះបីជាប្រទេសកម្ពុជាយើងទើបនឹងចាកចេញពីវិបត្តិនៃជំងឺកូវីដ-១៩ ជាបណ្តើរៗយ៉ាងណាក៏ដោយ ។ នេះជាសក្ខីភាពបង្ហាញអំពីវឌ្ឍនភាពលើគ្រប់ផ្នែករបស់បណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ និងការអនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់ខ្លួន ដើម្បីប្រែក្លាយស្ថាប័នបណ្តុះបណ្តាលមួយនេះឱ្យមានលក្ខណសម្បត្តិស្របតាមស្តង់ដាគុណភាពជាតិ និងអន្តរជាតិ ។

បន្ថែមលើនេះ ឯកឧត្តម សន្តិបណ្ឌិត ប្រធានគណៈអធិបតីក៏បានសម្តែងនូវការគាំទ្រផងដែរ ចំពោះគោលដៅយុទ្ធសាស្ត្រសំខាន់ៗ ដែលបណ្ឌិត្យសភានគរបាលកម្ពុជា បានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ៥ឆ្នាំបន្តរបស់ខ្លួន ពីព្រោះគោលដៅទាំងនេះបានឆ្លុះបញ្ចាំងនូវភារកិច្ចស្នូលរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់កងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល និងផែនការអភិវឌ្ឍន៍ធនធានមនុស្សរបស់ក្រសួងមហាផ្ទៃ ដោយឆ្លើយតបបានទាន់ពេលវេលាទៅនឹងការវិវត្តឥតឈប់ឈរនៃសភាពការណ៍សន្តិសុខជាតិ តំបន់ និងសកលលោក ។

គួរបញ្ជាក់ដែរថា៖ ក្នុងពិធីនោះក៏មានការប្រគល់-ទទួលរថយន្ត Pick Up ចំនួន ៦គ្រឿង ដល់បណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីប្រើប្រាស់ជាមធ្យោបាយនៅសាលានគរបាលជាតិភូមិភាគទាំង៦ ដោយរថយន្តទាំង ៦គ្រឿង នេះគឺជាអំណោយដ៏ថ្លៃថ្លារបស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្តល់ជូនបណ្ឌិត្យសភានគរបាលកម្ពុជា ៕



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល









តមកពីទំព័រ ២៨

## ពិធីបិទកិច្ចប្រជុំពិភាក្សា និងផ្សព្វផ្សាយ ...

មួយយ៉ាងសំខាន់សម្រាប់ជួយលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈប្រកបដោយបរិយាបន្ន ក្នុងការធ្វើកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ព្រោះថាព័ត៌មាន គឺជាមធ្យោបាយសម្រាប់ធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយដែលរដ្ឋបានដាក់ចេញឬសេវាសាធារណៈនានាដែលរដ្ឋត្រូវផ្តល់ជូនប្រជាពលរដ្ឋ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍បន្តថា៖ «**ព័ត៌មាន**» ជាមធ្យោបាយផ្សព្វផ្សាយអំពីសមិទ្ធផល និងស្នាដៃនានាដែលរាជរដ្ឋាភិបាលបានកសាងជូនជាតិមាតុភូមិ ហើយទន្ទឹមនេះ រាជរដ្ឋាភិបាលក៏ត្រូវការព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋវិញផងដែរ ដើម្បីដឹងពីតម្រូវការ និងបញ្ហាប្រឈមការលំបាក ក៏ដូចជាសំណូមពរផ្សេងៗ ដើម្បីទុកជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយដោះស្រាយ និងឆ្លើយតបជូនប្រជាពលរដ្ឋវិញ ។

ពាក់ព័ន្ធបញ្ហានេះ **សម្តេចក្រឡាហោម** ក៏បានចូលរួមផ្តល់នូវអនុសាសន៍ឱ្យអភិបាលរងនៃគណៈអភិបាលរាជធានី-ខេត្ត ទទួលបន្ទុកកិច្ចការនាំពាក្យត្រូវចូលរួមកាន់តែសកម្មថែមទៀតប្រកបដោយស្មារតីសាមគ្គីភាព និងបង្កើនទំនាក់ទំនងល្អ និងជិតស្និទ្ធជាមួយនឹងមន្ទីរអង្គភាពជំនាញជុំវិញរាជធានី-ខេត្ត ក៏ដូចជាការរៀបចំយុទ្ធសាស្ត្រព័ត៌មានឱ្យបានច្បាស់លាស់ ដើម្បីភាពជោគជ័យក្នុងការផ្តល់ព័ត៌មានឱ្យបានទូលំទូលាយ និងគ្រប់ជ្រុងជ្រោយក្នុងកិច្ចទទួលខុសត្រូវលើការដឹង និងការយល់របស់ប្រជាពលរដ្ឋដែលអាចចូលរួមយ៉ាងជិតស្និទ្ធទទួលសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងបរិយាបន្ន ។

ជាមួយគ្នានេះ **សម្តេចក្រឡាហោម** ក៏បានជម្រុញអ្នកនាំពាក្យគ្រប់ក្រសួង-ស្ថាប័ន រួមនឹងមន្ទីរអង្គភាពជំនាញជុំវិញរាជធានី-ខេត្ត ឲ្យចូលរួមសហការដោយឆន្ទៈខ្ពស់ ដើម្បីពង្រឹងគុណភាពនិងឯកភាពព័ត៌មានក្នុងជួររដ្ឋបាលរាជធានី-ខេត្ត ក្នុងន័យរៀបចំយន្តការច្រកព័ត៌មានទុកតែមួយ ហើយបញ្ចេញតាមច្រកតែមួយ តាមរយៈការបំផុសការផ្សព្វផ្សាយ(វេទិកាសាធារណៈ និងការឆ្លើយឆ្លងតាមរលកអាកាសវិទ្យុ និងបណ្តាញសង្គមនានា) នូវរាល់សមិទ្ធផលជាក់ស្តែងដែលកើតចេញពីការប្រឹងប្រែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា


SINCE 1997
WWW.SOKHAGROUP.COM
E: SOKHASUN@SOKHAGROUP.COM
Cell: 012 / 070 8 7777 6
SOKHA
PRINTING HOUSE
#970, STREET BETONG, PHUM ROUNG CHAK,
SANGKAT PHNOM PENH THMEY, KHAN SEN SOK
WE KNOW,
WHAT YOU WANT
MAGAZINE • CATALOGUE • MENU • BOOKLET • ANNUAL REPORT • DIARY • NOTEBOOK • BROCHURE • FLYER • CORPORATE IDENTITY • FOLDER •
CALENDAR • PAPER BAG • PLASTIC BAG • ECO BAG • KEY CHAIN • HAND FAN • PARASOL/UMBRELLA • PEN • T-SHIRT • CAP • BAG • CAKE BOX
• MEDICAL BOX • POSTER • BANNER • BILLBOARD • PRE-PAID CARD • ID CARD • CHEQUE • SECURITY CARD


VHP
VHP Global Co., Ltd.
ទឹកបរិធម្មជាតិ
ដើម្បីសុខភាព
ទិញឥឡូវនេះ ទទួលបាន
1 ឆ្នាំ
ធានាជូនសេវាកម្មបច្ចេកទេស
- ដឹកជញ្ជូនមិនគិតថ្លៃ
- ដំឡើងមិនគិតថ្លៃ
កង្ហាល Hatari
MODEL: W2-340S MODEL: HWJ-110 MODEL: W2-320 MODEL: W2-340
HOT COLD 4 FILTER FUNCTION
HWJ-110 13L
W2-320 10L
W2-340 27L
W2-340s 11L
W2-160p 10L
W2-320WH 9L
W2-320H 9L
W2-1000 10L
WH-UP 200 90L/H
HU-800 90L/H
មុខងារតម្រង់ 4 FILTER FUNCTION
Sediment
ច្រោះកករ (៣ខែប្ដូរម្ដង)
Pre -Carbon
ច្រោះសារធាតុគីមី (៦ខែប្ដូរម្ដង)
Post -Carbon
បង្កើនរសជាតិទឹក (៩ខែប្ដូរម្ដង)
UF-Membrane
កំចាត់មេរោគក្នុងទឹក (១២ខែប្ដូរម្ដង)
មេដាយទទួលស្គាល់ពី អាមេរិក អឺរ៉ុប និងកូរ៉េ
FDA
ISO 9001
ត្រូវការតំណាងលក់ផ្ដាច់មុខតាមតំបន់នីមួយៗ
VHP Globle
www.hyundaiwater.com
023 6666 919 / 069 5000 86
HYUNDAI
WACORTEC
ម៉ាស៊ីនចម្រោះទឹក
ព័ត៌មានបន្ថែម
អាស័យដ្ឋាន : ផ្ទះលេខ ៣៨C ផ្លូវ ៨០៨ សង្កាត់ទួលទំពូង॥ ខណ្ឌចំការមន រាជធានីភ្នំពេញ
អ៊ីម៉ែល : info@vhp-global.com / facebook.com/vhp.global

# ខែ កុម្ភៈ បង្ក្រាបគ្រឿងញៀនបាន ៥៨០ករណី ឃាត់ខ្លួនមនុស្ស ១.៤០០នាក់



ឧត្តមសេនីយ៍ទោ ឃឹង សារ៉ាត់ នាយកមន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ









ឧត្តមសេនីយ៍ទោ **ឃឹង សារ៉ាត់** នាយកមន្ទីរប្រឆាំងគ្រឿងញៀនអគ្គស្នងការដ្ឋាននគរបាលជាតិ បានបញ្ជាក់ប្រាប់ **ទស្សនាវដ្ដីមិត្តនគរបាល** ឱ្យដឹងថា៖ អនុវត្តតាមគោលការណ៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ និងក្រោមការដឹកនាំបញ្ជាផ្ទាល់ពី ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ ទទួលផែនប្រឆាំងគ្រឿងញៀន ឧត្តមសេនីយ៍ឯកប្រធាននាយកដ្ឋាន កណ្តាលនគរបាលយុត្តិធម៌ក្នុងខែកុម្ភៈកន្លងមកនេះ មន្ទីរប្រឆាំងគ្រឿងញៀនបានប្រមូលផ្តុំកម្លាំង និងបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានចំនួន ៥៨០ករណី ឃាត់ខ្លួន ១.៤០០នាក់ ( ស្រី ៨៣នាក់) និង៣០ដីកា ឃាត់ខ្លួន ៣០នាក់នាក់ ( ស្រី០១នាក់)ក្នុងនោះមាន៖ ជនជាតិខ្មែរ ចំនួន១.៣៦៧នាក់( ស្រី៨០នាក់)វៀតណាម ០២នាក់ ( ស្រី០១នាក់)ថៃ ០១នាក់ ចិន ២៦នាក់ ( ស្រី០២នាក់ )ចិនតៃវ៉ាន់ ០៤ នាក់ និង៣០ដីកា ឃាត់ខ្លួន ៣០នាក់ ស្រី០១នាក់ ក្នុងនោះជនជាតិ( ចិន០១ និងកូរ៉េខាងត្បូង០១) ចាប់យកសារធាតុញៀន មានទម្ងន់សរុប ៣០គ.ក្រ ៣១៦,៦៤ក្រាម ក្នុងនោះមាន៖ ( មេតំហ្វេតាមីន ICE ១០ គ.ក្រ ៧៩៨,១៣ក្រាម មេតំហ្វេតាមីន WY ១៥,៧៩ក្រាម កេតាមីន ៥គ.ក្រ ៩៥៩,៨៤ក្រាម អិចស្តាស៊ី ១៣គ.ក្រ ៥៣១,៩០ក្រាម នីមេតាហ្សេប៉ាម ១០,៩៨ក្រាម ដើមកញ្ឆា ១.៩៧៦ដើម ព្រមទាំងមធ្យោបាយ សម្ភារៈ និងទ្រព្យសម្បត្តិពាក់ព័ន្ធបទល្មើស មានរថយន្ត ១៨គ្រឿង ម៉ូតូ ១៥៩គ្រឿង ទូរស័ព្ទ ៥០៤គ្រឿង ជញ្ជីង ២៧គ្រឿង អាវុធខ្លី ០៣ដើម លុយខ្មែរ ៦,៧១០,៥០០៛ លុយថៃ ១.៨០០ បាត និងឧបករណ៍ សម្ភារៈមួយចំនួន ។ ទន្ទឹមនេះគ្រប់បណ្តាករណីទាំងអស់



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល









ត្រូវបានមន្ទីរប្រឆាំងគ្រឿងញៀន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត កសាងសំណុំរឿងបញ្ជូនជនសង្ស័យ និងវត្ថុតាង សម្ភារៈមធ្យោបាយទៅសាលាដំបូង ដើម្បីចាត់ការតាមនីតិវិធី ។



**ឧត្តមសេនីយ៍ទោ** នាយកមន្ទីរប្រឆាំងគ្រឿងញៀនបានបញ្ជាក់ទៀតថា៖ តាមការប្រៀបធៀបសន្ទស្សន៍ និងការវាយតម្លៃលើបទល្មើសដែលបង្ក្រាបបានក្នុងខែកុម្ភៈ ឆ្នាំ២០២៣នេះ ជាមួយនឹងខែកុម្ភៈ ឆ្នាំ២០២២ មានសន្ទស្សន៍ប្រែប្រួល ដូចជា ៖



-ចំនួនករណីក្នុង ខែកុម្ភៈ ឆ្នាំ២០២៣ មាន ៥៨០ករណី /៥៥១ករណី នៃខែកុម្ភៈ ឆ្នាំ២០២២ កើនឡើង ២៩ករណី ស្មើ ៥,២៦% ។

-ចំនួនជនសង្ស័យឃាត់ខ្លួន ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ មាន១.៤០០នាក់ ( ស្រី៨៣នាក់ ) / ១.១៧២នាក់( ស្រី ៦៦នាក់ )នៃខែកុម្ភៈ ឆ្នាំ២០២២ កើនឡើង ២២៨នាក់ ស្មើ ១៩,៤៥% ។

-ចំនួនដីកាចាប់ខ្លួនខែកុម្ភៈ ឆ្នាំ២០២៣ អនុវត្តបាន៣០ដីកា មនុស្ស៣០នាក់/២៧ដីកាមនុស្ស២៦នាក់នៃខែកុម្ភៈ ឆ្នាំ២០២២ កើនឡើង០៣ដីកា មនុស្ស០៤នាក់ ស្មើ ១១,១១% ។

-ដោយឡែកសន្ទស្សន៍សារធាតុញៀន ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ ប្រៀបធៀបទៅនឹងខែកុម្ភៈ ឆ្នាំ២០២២ មានការប្រែប្រួល ដូចជា ៖

-ខែកុម្ភៈ ឆ្នាំ២០២៣ គ្រឿងញៀន ចាប់យកសរុបមានទម្ងន់ ៣០គ.ក្រ ៣១៦,៦៤ក្រាម

-ខែមករា ឆ្នាំ២០២២ គ្រឿងញៀន ចាប់យក សរុបមានទម្ងន់ ៣៩គ.ក្រ ០៥៩,៨៥ក្រាម

មានការថយចុះជាងមុន ទម្ងន់៨គ.ក្រ ៧៤៣,២១ក្រាម ស្មើ២២,៣៨% ។

**ឧត្តមសេនីយ៍ទោ** នាយកមន្ទីរប្រឆាំងគ្រឿងញៀន បានបញ្ជាក់ឱ្យដឹងបន្ថែមទៀតថា៖ ផ្អែកតាមលទ្ធផលកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ និងខែមករា ឆ្នាំ២០២២ យើងអាចវាយតម្លៃ បានថា៖ លទ្ធផលបង្ក្រាបមាន ៥៨០/៥៨០ករណី កើនឡើង ០ករណី ស្មើ០% និងចំនួនមនុស្សឃាត់ខ្លួន ១.៤០០នាក់ / ១.៤៥៤នាក់ ថយចុះ ៥៤នាក់ ស្មើ ៣,៧១% និងបរិមាណគ្រឿងញៀន ចាប់យក មាន ៣០គ.ក្រ ៣១៦,៦៤ក្រាម / ៩៤គ.ក្រ ៨៥៣,៦១ក្រាម ថយចុះទម្ងន់ ៦៤គ.ក្រ ៥៣៦,៩៧ក្រាម ស្មើ ៦៨,០៣% ។»



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 9:55 AM

# មហាសង្ក្រាន្ត

## ឆ្នាំថោះ បញ្ចស័ក

### ពុទ្ធសករាជ ២៥៦៧

### គ្រិស្តសករាជ ២០២៣ មហាសករាជ ១៩៤៥ ចុល្លសករាជ ១៣៨៥

### សុភមស្តុ! វរមង្គលាជយាតិបក




ព្រះពុទ្ធសករាជព្រះសាសនាអតិក្កន្តាកន្លងទៅហើយបាន២៥៦៦ ត្រឹមថ្ងៃព្រហស្បតិ៍១៥កើត ខែពិសាខ លុះដល់ថ្ងៃសុក្រ១រោច ខែពិសាខ ឆ្នាំថោះបញ្ចកទៅចូលពុទ្ធសករាជ២៥៦៧ ។

នឹងគណនាឆ្នាំថោះឥឡូវនេះ សង្ក្រាន្តចូលនៅថ្ងៃសុក្រ៩រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែមេសា គ.ស.២០២៣ វេលាម៉ោង១៦:00នាទី ។ ពេលនោះព្រះអាទិត្យចេញពីមីនរាសីទៅឋិតនៅមេសរាសី តាមផ្លូវគោវិថី គឺផ្លូវកណ្តាលមានទេវធីតាមួយព្រះអង្គជាមគ្គនាយិកាព្រះនាម **កិមិរាទេវី** ជារាជបុត្រីទី៦ នៃកបិលមហាព្រហ្មគង់នៅចាតុម្មហារាជិកាទ្រង់អម្ពរពណ៌**សេត**(**ស**)លម្អនៅព្រះកាណ៌ដោយសៀត **ផ្កាចង្កុលណី** អាភរណៈ**បុស្សរាគ៌ម** ភក្សាហារទ្រង់ **ចេកណាំវ៉ា** ព្រះហត្ថស្តាំទ្រង់**ព្រះខ័ន្ធ** ព្រះហស្តឆ្វេងទ្រង់**ពិណ** ទ្រង់គង់អង្គុតពាក់ឆៀងលើកព្រះនេត្រនៅលើខ្នង**មហឹង្សា** (ក្របី) ជាយានពាហនៈ។ ទើបនាំអស់ទេវបុត្រ ទេវធីតាទាំងមួយសែនកោដិហោះទៅកាន់គុហាកែវ **ធម្មមាលី** នាទីភ្នំកៃលាស់ ខេត្តហិមពាន្ត ជាទីតំកល់ទុកនូវព្រះសិរសាកបិលមហាព្រហ្មដែលតំកល់លើពានមាសនាំមកដង្ហែប្រទក្សិណភ្នំព្រះសុមេរុរាជតាមផ្លូវព្រះអាទិត្យចរចំនួន៦០នាទី ។ ទើបនាំយកទៅតម្កល់ទុកកន្លែងដើមវិញ ហើយប្រជុំទេវបុត្រ ទេវធីតាទាំងមួយសែនកោដិចូលទៅស្រង់ **ទឹកអនោតត្តមហាស្រះ** ដែលមានទឹកហូរចេញពីបំពង់ថ្មកែវដែលជាមាត់**គោឧសភរាជ**ទាំង៧ព្រះដាក់ក្រេមក្សាន្តព្រះរាជហឫទ័យ ហើយនាំគ្នាចូលទៅសមោទានរក្សាសីល ដោយសោមនស្សរីករាយគ្រប់ៗព្រះអង្គ ក្នុងភគវតីសភាសាលាដែលព្រះវិស្សកម្មទេវបុត្រនិមិត្តថ្វាយ ដើម្បីបន្ទោបង់អពមង្គលឱ្យជ្រះស្រឡះ ហើយចម្រើននូវសិរីសួស្តីជ័យមង្គលជន្មាយុយឺនយូរដល់ទេវតា និងមនុស្សសត្វផងទាំងឡាយ តាំងពីឆ្នាំថ្មីចូលមកនេះបានទូលទូលាយសុខក្រេមក្សាន្តតរៀងទៅ ។

**មហាសង្ក្រាន្ត ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧ មហាសករាជ ១៩៤៥ ចុល្លសករាជ១៣៨៥**

ថ្ងៃសុក្រ ៩រោច ខែចេត្រត្រូវនឹងថ្ងៃទី១៤ ខែមេសា គ.ស២០២៣ វេលាម៉ោង១៦:00នាទី រល្វាចជាថ្ងៃចូលឆ្នាំថោះបញ្ចស័ក(ជាវារៈ មហាសង្ក្រាន្ត)។

ថ្ងៃសៅរ៍ ១០រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៥ មេសា គ.ស ២០២៣ ជាវារៈវ័នបត ។

ថ្ងៃអាទិត្យ ១១រោច ខែចេត្រត្រូវនឹងថ្ងៃទី១៦ ខែមេសា គ.ស ២០២៣ នៅវេលាម៉ោង២០ និង០២នាទី ២៤វិនាទី ជាវារៈឡើងស័កគម្រប់ជាសង្ក្រាន្តបីថ្ងៃគ្រប់បរិបូរណ៍ចូលជាសកលឆ្នាំថោះបញ្ចស័ក មហាសករាជ១៩៤៥ ចុល្លសករាជ ១៣៨៥ តទៅ ។

នៅក្នុងឱកាសសង្ក្រាន្តទាំងបីថ្ងៃ សូមអស់ប្រជាពលរដ្ឋប្រុសស្រីផង



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/wvlq/




ទាំងឡាយរៀបចំពលិការគ្រឿងសក្ការបូជារុចប្រទីប ផ្កាឈាថ្វាយព្រះអាទិត្យ និងទទួលស្វាគមន៍ទេវបុត្រ ទេវធីតាឆ្នាំថ្មី ហើយទំលះបង់ចិត្តអាក្រក់អន្ធពាលឡើយ ជាចិត្តអប្រីយ៍ជាប់ដោយគំនុំគុំគួនព្យាបាទឈ្នានីស ដែលកើតមានក្នុងឆ្នាំចាស់ឱ្យជ្រះស្រឡះតាំងចិត្ត ប្រព្រឹត្តល្អប្រកបដោយមេត្តា ករុណា មុទិតា ឧបេក្ខា និងបញ្ញា ធ្វើបុណ្យសុន្ទរទានតាមប្រពៃណីរក្សាសីល ប្រាំឱ្យបានជាប់ជានិច្ច នោះទេវធីតានឹងឱ្យពរសព្ទ សាធុការលោកអ្នកនឹងមាន សិរីសួស្តី សុភមង្គល វិបុលសុខគ្រប់ប្រការតាំងពីឆ្នាំថ្មីនេះតរៀងទៅ ។

## របៀបទទួលទេវតា

របៀបទទួលទេវតាតាមទំនៀមពីបុរាណរៀង រហូតមកត្រូវរៀបរានទទួលទេវតានៅខាងមុខផ្ទះមួយ សម្រាប់តាំងគ្រឿងពលិការផ្សេងៗ ។ ត្រូវរៀបក្រាល សំពត់ពណ៌ស ហើយរៀបចំនូវគ្រឿងសក្ការបូជា ទេវតាមានជាអាទិ៍ បាយសី៩ថ្នាក់មួយគូ បាយសី៧ ថ្នាក់មួយគូ បាយសី៥ថ្នាក់មួយគូ បាយសី៣ថ្នាក់មួយ គូ បាយសីប៉ាឆាមមួយគូ ស្លាធម៌មួយគូ ទឹកអប់មួយគូ ទៀន៥ ធូប៥ ណាច៥ ផ្កា៥ ដាក់លើជើងពាន ១គូ ចេកនួន ចេកណាំវ៉ាដាក់ លើជើងពានមួយគូផ្លែឈើ ១១មុខ (១) រៀបដាក់ជើងពាន ១១គូ ដូងខ្ចីមួយគូ ទឹកស្អាតពីរកែវ ។ ស្រេចហើយនៅវេលាម៉ោងដែល ទេវតាចុះមកត្រូវជួបប្រជុំក្រុមគ្រួសារ ដើម្បីថ្វាយបង្គំ ព្រះនមស្សការព្រះអាទិត្យសមាទានសីល ហើយ តាំងចិត្តឱ្យបានស្អាតបរិសុទ្ធជ្រះស្រឡះនូវមន្ទិលទាំង ពួងតម្កល់ចិត្តរំពឹងគិតទៅលើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរឭក លុះចប់ពិធីទទួលទេវតា ។

ចំពោះបាយសី៩ថ្នាក់ ៧ថ្នាក់ ជាទំនៀមមាន ចែងនៅក្នុងសៀវភៅព្រះរាជពិធីទ្វាទសមាស និង មានអនុវត្តនៅព្រះបរមរាជវាំង តែចំពោះប្រជារាស្ត្រ គួរធ្វើត្រឹម៥ថ្នាក់ចុះមកឬរៀបត្រឹមគ្រឿងសក្ការបូជា ដែលមានទៀនប្រាំ ធូបប្រាំ ស្លាធម៌កូនចេកមួយគូក៏ ល្មមសមគួរដែរ ។ ចំពោះផ្លែឈើសម្រាប់ប្រជារាស្ត្រ គួររៀបចំឱ្យបានត្រឹម៣ឬ៥មុខក៏ជាការប្រសើរគឺទៅ តាមឆន្ទៈរបស់ខ្លួន ។ នៅគ្រប់ផ្ទាយទាំងអស់ត្រូវ ដាក់ផ្កាម្លិះភ្ជួងពីលើគ្រប់ផ្ទាយនៅលើជើងពាន និង លើបាយសីត្រូវដោតទៀនហើយអុតបំភ្លឺ ៕

**ដកស្រង់ចេញពី ៖ មហាសង្ក្រាន្ត**

គណៈកម្មការស្រាវជ្រាវវិជ្ជាហោរាសាស្ត្រ និង
ប្រពៃណីទំនៀមទម្លាប់ខ្មែរ



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# នគរបាលរាជធានីភ្នំពេញ បង្រ្កាបបទល្មើសគ្រប់ប្រភេទ បានចំនួន ៣៦ករណី និងឃាត់ខ្លួនចំនួន ៥៨នាក់



ឧត្តមសេនីយ៍ទោ សុខ លី ស្នងការរងទទួលផែននគរបាលព្រហ្មទណ្ឌ

តាមការបញ្ជាក់របស់ ឧត្តមសេនីយ៍ទោ **សុខ លី** ស្នងការរងនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានបញ្ជាក់ឱ្យដឹងថា៖ ខែកុម្ភៈកន្លងមកនេះ សភាពការណ៍បទល្មើសព្រហ្មទណ្ឌក្នុងទូទាំងរាជធានីភ្នំពេញកើតឡើង៤៧លើក/៥២លើក ថយចុះ ០៥លើក ស្មើ៩.៦១% (ស្លាប់ ០២នាក់ របួស ០៧នាក់) បាត់បង់ម៉ូតូ ១១គ្រឿង សម្ភារៈ និងលុយកាក់មួយចំនួន ។ មូលដ្ឋានកើតមានបទល្មើស ខណ្ឌ (ដូនពេញ ០៩លើក ពោធិ៍សែនជ័យ ០៨លើក មានជ័យ០៧លើក ទួលគោក ០៥លើក ដង្កោ ០៤លើក កំបូល ០៤លើក សែនសុខ ០២លើក បឹងកេងកង ០២លើក ជ្រោយចង្វារ ០២លើក ចំការមន ០១លើក ព្រែកព្នៅ ០១លើក ឫស្សីកែវ ០១លើក និងខណ្ឌច្បារអំពៅ ០១លើក) ក្នុងនោះ បទល្មើសឧក្រិដ្ឋ កើតឡើង ០៨លើក/១០លើក (ស្លាប់០២នាក់ របួស០១នាក់) មានដូចជាលួចមានស្ថានទម្ងន់ទោស ០៥លើក/ ០៧លើក លួចមានស្ថានទម្ងន់ទោស( ប្រើអាវុធ) ០១លើក/០៣លើក លួចមានស្ថានទម្ងន់ទោស( ប្រើប្រាស់មធ្យោបាយផ្សេងៗ)០៤/០៤លើក ឃាតកម្ម ០២លើក/០២លើក និងរំលោភសេពសន្ថវៈ០១លើក/០១លើក ។ ទន្ទឹមនេះ បទល្មើសមជ្ឈិមកើតឡើង ៣៩លើក/៤២លើក (របួស០៦នាក់ )មានដូចជាលួច ២០លើក/១៧លើកឆក់១៤លើក/១៥លើក ឆបោក ០លើក/០១លើក អំពើហិង្សាដោយចេតនា ០៥លើក/០៦លើក បំពានខាងផ្លូវភេទផងទៀត០/០១លើក និងប្រើប្រាស់អាវុធខុសច្បាប់០លើក/០២លើក ។







ឧត្តមសេនីយ៍ទោ ស្នងការរង បានបញ្ជាក់ទៀតថា៖ ប្រឈមមុខចំពោះបទល្មើសដែលបានកើតឡើងនេះ កម្លាំង



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល













ជំនាញក្រោមការដឹកនាំ និងចង្អុលណែនាំពីសំណាក់ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស ថេត** អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ

បានបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស ដែលជាលទ្ធផលលើងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ បាន៣៦ករណី ឃាត់ខ្លួន ៥៨នាក់ បង្ក្រាបជាក់ស្តែង (បទល្មើសឧក្រិដ្ឋ ០៤ករណី ឃាត់ខ្លួន០៦នាក់ បទល្មើសមជ្ឈិម ៣២ករណី ឃាត់ខ្លួន ៥២នាក់ ) និងបង្ក្រាបតាមដីកា ០២ដីកា ឃាត់ខ្លួន ០២នាក់ (បទល្មើសមជ្ឈិម) ដែលក្នុងនោះមាន៖

បទល្មើសឧក្រិដ្ឋ បង្ក្រាបបាន ០៤ករណី ឃាត់ខ្លួន ០៦នាក់ មានដូចជា៖

+លួចមានស្ថានទម្ងន់ទោស ០១ករណី ឃាត់ខ្លួន០១នាក់

+លួចមានស្ថានទម្ងន់ទោស(ប្រើប្រាស់មធ្យោបាយផ្សេងៗ) ០១ករណី ឃាត់ខ្លួន ០១នាក់

+មនុស្សឃាត ០២ករណី ឃាត់ខ្លួន ០៤នាក់

+រំលោភសេពសន្ថវៈ ០១ករណី ឃាត់ខ្លួន ០១នាក់ ។

ទន្ទឹមនេះបទល្មើសមជ្ឈិម បង្ក្រាបបាន ៣២ករណី ឃាត់ខ្លួន ៥២នាក់ មានដូចជា៖ លួច១៥ករណី ឃាត់ខ្លួន ២១នាក់ ឆក់ ១៣ករណី ឃាត់ខ្លួន ២០នាក់ អំពើហិង្សាដោយចេតនា ០៤ករណី ឃាត់ខ្លួន១១នាក់ រឹបអូសវត្ថុតាង អាវុធខ្លី ០១ដើម កាំបិត ០៣ដើម រថយន្ត ០២គ្រឿង ម៉ូតូ ២៧គ្រឿង និងសម្ភារៈពាក់ព័ន្ធមួយចំនួន រីឯជនសង្ស័យ និងវត្ថុតាងត្រូវបានបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញចាត់ការតាមផ្លូវច្បាប់ ។

ជាការកត់សម្គាល់ គឺក្នុងចំណោមជនសង្ស័យឃាត់ខ្លួន ៥៨នាក់ ពិនិត្យឃើញមានផ្ទុកសារធាតុញៀន ចំនួន ៤៤នាក់ ស្មើនឹង ៧៥,៨៦% ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សកម្មភាពប្រតិភូ ស ម ន នាំយក ថវិកាផ្តល់ជូនដល់គ្រួសារសព សមាជិក-សមាជិកា ដែលទទួលមរណភាព និងបាត់បង់សមត្ថភាពការងារ



**ឧត្តមសេនីយ៍ឯក ស ថេត** ប្រធានគណៈកម្មាធិការការមូលដ្ឋានស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ អញ្ជើញប្រគល់ ថវិកា ស ម ន ជូនដល់លោកវរសេនីយ៍ត្រី ជា គឹមហួរ ដែលភរិយាទទួលមារណភាព ។

**ឧត្តមសេនីយ៍ទោ ម៉ែន លី** ប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ប្រគល់ថវិកា ស ម ន ជូនដល់លោកអនុសេនីយ៍ឯក ញ៉េម ដុង ដែលភរិយាទទួលមរណភាព ។





**ឧត្តមសេនីយ៍ត្រី គាត ប៊ុនថាន** អនុប្រធានគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ ប្រគល់ថវិកា ស ម ន ជូនលោកអនុសេនីយ៍ឯក ព្រិន រដ្ឋា ដែលភរិយាទទួលមរណភាព ។

**ឧត្តមសេនីយ៍ទោ ឬត សុធី** ប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ ប្រគល់ថវិកា ស ម ន ជូនលោកស្រី សោម សុភាព ត្រូវជាកូនសពលោកអនុសេនីយ៍ទោ វ៉ាន់ ស៊ីណាត ។



សូមលំអោនកាយរំលែកទុក្ខយ៉ាងក្រៀមក្រំ ចំពោះមន្ត្រីនគរបាលជាតិ
ដែលបានពលីជីវិតក្នុងបេសកកម្មនានានៃបុព្វហេតុជាតិ មាតុភូមិ និង
សូមបួងសួងឱ្យវិញ្ញាណក្ខន្ធបងប្អូន ឆាប់បានទៅកាន់សុខគតិភព។



**៣ការពារ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




**ឧត្តមសេនីយ៍ត្រី សុខ ដារិន** អនុប្រធានគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋាននគរបាលទេសចរណ៍ ប្រគល់ថវិកា ស ម ន ជូនដល់លោកអនុសេនីយ៍ឯក លឹម ជាតិ ដែលភរិយាទទួលមរណភាព ។

**ឧត្តមសេនីយ៍ត្រី ឡុង គីម** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពត ប្រគល់ថវិកា ស ម ន ជូនដល់លោក គីម ចំរើន ត្រូវជាកូនប្រុសសពលោកវរសេនីយ៍ត្រី មិន ផល ។






**ឧត្តមសេនីយ៍ត្រី អៀង មករា** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តសៀមរាប ប្រគល់ថវិកា ស ម ន ជូនដល់លោកវរសេនីយ៍ទោ សោម វិជេត ដែលភរិយាទទួលមរណភាព ។

**ឧត្តមសេនីយ៍ត្រី វង្ស វិត** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ប្រគល់ថវិកា ស ម ន ជូនដល់គ្រួសារសពលោកអនុសេនីយ៍ឯក ស៊ិន សុធារិទ្ធ ។





**ឧត្តមសេនីយ៍ត្រី សេង គឹមឃន** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកណ្ដាលប្រគល់ថវិកា ស ម ន ជូនលោក សុវណ្ណ មុន្នីបញ្ញា ត្រូវជាកូនប្រុសសពលោកអនុសេនីយ៍ទោ ម៉ម វណ្ណា ។

**វរសេនីយ៍ឯក ស្វាយ ស៊ីប៊ុណ្ណា** លេខាធិការគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ប្រគល់ថវិកា ស ម ន ជូនលោកស្រី ឃិន គឹមហ៊ាង ត្រូវជាភរិយាសពលោកព្រិន្ទបាលឯក ម៉ម ស្រ៊ី ។





**៣កុំ ៖** -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ដើមឆ្នាំ២០២៣ គ្រោះមហន្តរាយធម្មជាតិរញ្ជួយដីនៅប្រទេសតួកគី និងប្រទេសស៊ីរី កំរិតញ័រ ៧.៨ តាមរង្វាស់រិចទ័រ សម្លាប់មនុស្ស កើនឡើងដល់ជាង ៤ម៉ឺន៦ពាន់នាក់ហើយ




**តួកគី-ស៊ីរី ៖** ភាពសោកសៅដែលបង្កឡើងដោយគ្រោះមហន្តរាយធម្មជាតិពោល គឺការរញ្ជួយដីបានកើតមានឡើងនៅតាមបណ្តោយព្រំដែនប្រទេសតួកគីជាប់នឹងប្រទេសស៊ីរី ។ ការរញ្ជួយនេះទៀតសោតក៏បង្កការភ្ញាក់ផ្អើលដល់ប្រទេសក្បែរដទៃទៀត មានប្រទេសនៃកោះសៃប្រើស និងលីបង់ រួមទាំងប្រទេសអ៊ីស្រាអ៊ែលផងដែរ ។



តាមបណ្តាញផ្សព្វផ្សាយអន្តរជាតិនានា បានលើកឡើងឱ្យដឹងដែរថា អាកាសធាតុចុះត្រជាក់ខ្លាំងដែលបង្កទៅជាឧបសគ្គដល់ដំណើរកិច្ចការស្រាវជ្រាវរុករកជនរងគ្រោះ។ សេចក្តីរាយការណ៍ដែលបានលើកឡើងបន្ថែមទៀតថា រហូតមកទល់នឹងពេលនេះ តួលេខអ្នកស្លាប់បានកើនឡើងដល់ខ្ទង់ជាងបួនម៉ឺនប្រាំមួយពាន់នាក់ទៅហើយ និងរងរបួសរាប់សិបម៉ឺននាក់ផ្សេងទៀតដែលតួលេខនេះទៀតសោតអាចនឹងនៅតែបន្តកើនឡើង ។ ខណៈដំណើរបើកប្រតិបត្តិការ រុករក និងស្រាវជ្រាវនៅតែបន្តដោយក្រុមអាជ្ញាធរបានប្រើប្រាស់កម្លាំងចម្រុះរួមទាំងក្រុមអ្នកស្ម័គ្រចិត្តរាប់ពាន់នាក់ផ្សេងទៀតក៏បានចូលរួមក្នុងព្រឹត្តិការណ៍ដ៏សោកសៅនេះដែរ ។

ចំណែកឯអង្គការសហប្រជាជាតិឯណោះវិញ បានធ្វើការព្រមានថា គ្រោះមហន្តរាយធម្មជាតិចេញពីការរញ្ជួយដីនេះបានបង្កនូវវិនាសកម្មកំរិតទ្រង់ទ្រាយធំដែលហួសពីការរំពឹងទុកទៅទៀត។ ការស្រាវជ្រាវរុករកជនបាត់ខ្លួនបានបន្តធ្វើឈានចូលដល់ថ្ងៃទី៤ហើយ (គិតត្រឹមថ្ងៃសុក្រទី១០ ខែកុម្ភៈ)ឆ្នាំ២០២៣ ស្របពេលការលំបាកកាន់តែខ្លាំង ជាពិសេសពេលរាត្រីដោយសារតែអាកាសធាតុចុះត្រជាក់ខ្លាំងនាំឱ្យពិបាកដល់ក្រុមការងារចុះជួយសង្គ្រោះនេះអាចចាត់ទុកថា ជាហេតុការណ៍ដ៏សោកសៅបំផុតលើកដំបូង



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







នៅក្នុងប្រទេសតួកគី ដែលមានលក្ខណៈទ្រង់ទ្រាយធំសម្បើមបែបនេះ ។

**តើប្រមុខដឹកនាំប្រទេសតួកគី និយាយថា ដូចម្តេចខ្លះពីរឿងដ៏សោកសង្រេងមួយនេះ?**

ស្ថិតនៅក្នុងអន្តរកាលដ៏លំបាកលំបិន និងកំពុងតែឆ្លងកាត់លើបញ្ហាគ្រោះមហន្តរាយធម្មជាតិមួយនេះ លោកប្រធានាធិបតីតួកគី **តាយីប អ៊ើដូហ្គាន់** បាន ហៅព្រឹត្តិការណ៍រញ្ជួយដីថា "**គ្រោះមហន្តរាយដ៏សោកសៅប្រចាំប្រទេស**"។ ការមានប្រសាសន៍បែបនេះបានធ្វើឡើងនៅឯទីតាំងមួយកន្លែងដែលក្រុមមន្ត្រីជួយសង្គ្រោះកំពុងតែខុតខែងខុតជើង ដើម្បីរត់ប្រណាំងជាមួយនឹងពេលវេលា ដើម្បីធ្វើយ៉ាងណាឱ្យទាន់សភាពការណ៍ដាក់ស្តែងដែលជនរងគ្រោះកំពុងតែត្រូវការជួយបន្ទាន់បំផុតនោះ ។

រដ្ឋាភិបាលប្រទេសតួកគី បានប្រកាសដាក់តំបន់រងគ្រោះស្ថិតនៅក្នុងភាពអាសន្ន និងប្រកាសកាន់ទុក្ខកិច្ចជាតិរយៈពេល៧ថ្ងៃ ដើម្បីចូលរួមសម្តែងនូវមរណទុក្ខចំពោះបុគ្គលដែលបាត់បង់ដោយសារតែគ្រោះមហន្តរាយធម្មជាតិដ៏ធំធេងនេះ។

កាលពីថ្ងៃព្រហស្បតិ៍កន្លងទៅនេះ ធនាគារពិភពលោកបានសន្យាថានឹងជួយលើកម្ពស់ទឹកប្រាក់ប្រមាណជា(១.៧៨ពាន់លានដុល្លារអាមេរិក)ឬស្មើនឹង(១.៣៨ពាន់លានផោន)។ ក្នុងទំហំទឹកប្រាក់ជំនួយនេះ ត្រូវគេផ្តល់ជើគម្រោងស្តារឡើងវិញនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគាំពារតំបន់ដែលរងគ្រោះដោយសារតែឥទ្ធិពលនៃការរញ្ជួយ ។ មិនតែប៉ុណ្ណោះ ក៏មានកញ្ចប់ជំនួយផ្សេងៗទៀត

☞ ៦១



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា






តមកពីទំព័រ ៦០

## ដើមឆ្នាំ ២០២៣ គ្រោះមហន្តរាយធម្មជាតិ...

មកពីសហរដ្ឋអាមេរិក បានសន្យាថានឹងជួយដល់ប្រទេសតួកគី ក្នុងទំហំទឹកប្រាក់ប្រមាណជា៨៥លានដុល្លារអាមេរិក (ទឹកប្រាក់នេះជួយប្រទេសទាំងពីរដែលរងគ្រោះ ពោលគឺប្រទេសតួកគី និងប្រទេសស៊ីរីដែលកំពុងតែត្រូវការជំនួយជាបន្ទាន់)។

### ដំណើការជួយសង្គ្រោះ

ស្របពេលដំណាលគ្នានេះដែរ អាជ្ញាធរប្រទេសតួកគីបានប្រើប្រាស់កម្លាំងសកម្មលើប្រតិបត្តិការជួយសង្គ្រោះ និងក្រុមដឹកកកាយមានរហូតដល់ទៅ១សែននាក់ឯណោះ ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ ពោលគឺរថយន្តដឹកជនរងគ្រោះចេញពីកន្លែងកើតហេតុនៅមានកំរិតនៅឡើយ មានន័យថា កង្វះខាតច្រើនដែលមិនអាចដឹកជញ្ជូនអ្នករងរបួសយកទៅព្យាបាលបានទាន់ពេលវេលា ។

លោក **អាន់តូនីញ៉ូហ្គាធីរ៉េស** (Antonio Guterres) ជាប្រមុខអង្គការសហប្រជាជាតិ បានព្រមានថាវាជាគ្រោះអាសន្នធម្មជាតិដែលមានលក្ខណ:ទ្រង់ទ្រាយធំនៅក្នុងប្រទេសតួកគី និងនៅក្នុងប្រទេសស៊ីរី ស្របពេលដែលប្រទេសនេះបាននិងកំពុងតែប្រឈមមុខទៅនឹងសង្គ្រាមរ៉ាំរ៉ៃមិនទាន់ត្រូវបានបញ្ចប់នៅឡើយរទេរហូតមកទល់នឹងជួបប្រទះគ្រោះមហន្តរាយធម្មជាតិរញ្ជួយដីនេះ។

កាលពីថ្ងៃព្រហស្បតិ៍ កន្លងទៅក្រុមជំនួយមនុស្សធម៌ស្ថិតនៅក្រោមឆ័ត្រអង្គការសហប្រជាជាតិបានធ្វើដំណើរឆ្លងកាត់ព្រំដែនចេញពីប្រទេសតួកគីឆ្ពោះទៅកាន់តំបន់ភាគពាយ័ព្យប្រទេសស៊ីរី បានប្រឈមមុខទៅនឹងភាពលំបាកខ្លាំងដោយសារតែកងយោធាស៊ីរី បិទច្រកមិនអាចចេញចូលបានដោយសេរីនោះឡើយ ដែលកត្តានាំឱ្យមានសភាពស្មុគ្រស្មាញដល់ដំណើរការងារមនុស្សធម៌នៅក្នុងតំបន់រងគ្រោះនៃប្រជាជាតិទាំងពីរ ពោលគឺ ស៊ីរី ហើយប្រទេសតួកគី ។

ក្រុមអ្នកឯកទេសភូមិសាស្ត្ររបស់សហរដ្ឋអាមេរិក បានលើកឡើងថាអាចនឹងមានគ្រោះរញ្ជួយដីជាលើកទី២បន្ថែមទៀត ដែលករណីនេះ មានលក្ខណ:ប្រហាក់ប្រហែលគ្នាទៅនឹងគ្រោះមហន្តរាយធម្មជាតិដែលបានកើតមានឡើងនៅក្នុងតំបន់ភាគពាយ័ព្យប្រទេសតួកគី កាលពីឆ្នាំ១៩៩៩ ដែលកាលណោះបានសម្លាប់មនុស្សប្រមាណជា១៧,០០០នាក់ឯណោះ ។ គ្រាន់តែនៅក្នុងប្រទេសស៊ីរីតែមួយតួលេខអ្នកស្លាប់បានកើនឡើងដល់ទៅ៤០,៦៤៧នាក់



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល





និងរាប់ពាន់នាក់ផ្សេងទៀតរងរបួស ។

**ចុះអង្គការសុខភាពពិភពលោកវិញ គេមើលឃើញបែបណាដែរ?**

ចំពោះអង្គការសុខភាពពិភពលោក (WHO) កាលពីដើមសប្តាហ៍កន្លងទៅ ធ្លាប់ព្រមានអំពីគ្រោះមហន្តរាយមនុស្សធម៌ណាមដល់លើកទី២បន្តទៀតទៅលើជនរងគ្រោះដែលនៅរស់រានមានជីវិត ដោយសារតែពួកគេត្រូវទៅនៅក្នុងជម្រកបណ្តោះអាសន្ន ខ្វះអាហារ ទឹកប្រើប្រាស់ និងឱសថព្រោះពេលនេះត្រូវការជាបន្ទាន់ និងត្រូវដោះស្រាយជាបន្ទាន់ស្របពេលប្រតិបត្តិការរុករកនៅតែធ្វើបន្តនៅឡើយមិនទាន់បានបញ្ចប់ ។

លោកវេជ្ជបណ្ឌិត **ហានស៍ ក្លូក** (Hans Kluge) នាយកប្រចាំតំបន់របស់អង្គការសុខភាពពិភពលោក បានរៀបរាប់ប្រាប់ដល់បណ្តាញផ្សព្វផ្សាយ អង់គ្លេស **ប៊ីប៊ីស៊ី** ថាបុគ្គលិករបស់អង្គការសុខភាពពិភពលោក ត្រូវសម្រាកនៅលើរថយន្តដោយមិនអាចចេញទៅណារួចខណៈជនរងគ្រោះរាប់រយរាប់ពាន់នាក់បានចូលមកដល់ជាបណ្តើរៗត ម្រូវឱ្យនៅរង់ចាំដើម្បីទទួលព្យាបាលពួកគេ ។

លោកវេជ្ជបណ្ឌិតរូបនេះ បានបន្តទៀតថា សហគមន៍ទាំងឡាយនៅក្នុងប្រទេសស៊ីរី គេងតែពឹងផ្អែកទាំងស្រុងទៅលើអាងស្តុកទឹក ខណៈដែលទឹកប្រើប្រាស់កំពុងតែខ្វះខាត ដូច្នេះពួកគេនឹងប្រឈមមុខទៅនឹងគ្រោះអាសន្នបន្ថែមមួយជាន់ទៀត ដែលហាក់ដូចជាទុក្ខភ្នែតលើទុក្ខអញ្ចឹងដែរ ។

តាមសេចក្តីរាយការណ៍បានឱ្យដឹងបន្ថែមទៀតថា នៅក្នុងដំណើរប្រតិបត្តិការជួយសង្គ្រោះរយៈពេលដំបូងគេរកឃើញមនុស្សនៅរស់រានមានជីវិតប្រមាណជា ៧២នាក់ ប៉ុន្តែក្រោយរពេល៨០ម៉ោងបន្តមកទៀតគេបានរកឃើញកុមារម្នាក់មានឈ្មោះថា **ម៉េលដា អាតាស៍** (Melda Adtas ) មានអាយុ១៦ឆ្នាំ នៅរស់រានមានជីវិតនៅឡើយដោយសារតែរូបគេកប់នៅក្រោមគំនរបាក់បែករបស់អគារ ។

**គួរបញ្ជាក់ដែរថា** ចំនួនអ្នកស្លាប់នៅប្រទេសតួកគីបានកើនឡើងដល់ ៤០,៦៤២នាក់ ដោយឡែកប្រទេសស៊ីរី ចំនួនអ្នកស្លាប់បានកើនឡើងដល់ ៥,៨០០នាក់ ។ ចំណែកការខូចខាតអគារ និងអាផាតមិន (Apartments) វិញ កើនឡើងដល់ទៅចំនួន ២៦៤,000 ទីតាំង ឯណោះ ។ ដោយឡែកចំពោះសហគមន៍អន្តរជាតិវិញបានប្រកាសជួយយ៉ាងគ្រាំងគ្រាតដែលរួមមានអង្គការសហប្រជាជាតិ អង្គការសុខភាពពិភពលោក សហរដ្ឋអាមេរិក បារាំង អង់គ្លេស និងបណ្តាប្រទេសផ្សេងៗជាច្រើនទៀត៕

ប្រែសម្រួលខ្លឹមសារ៖ អនុ.ទោ ប្រាក់ សម្ផស្ស

ប្រភព ៖ AFP/BBC/Reuters



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សម្តេចក្រឡាហោម អនុញ្ញាតឲ្យឯកអគ្គរាជទូតថ្មីនៃប្រទេសជប៉ុន ប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ



កាលពីព្រឹកថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឱ្យ ឯកឧត្តម **អ៊ូអិណុ អាត់ស៊ូស៊ី** ( UENO Atsushi ) ឯកអគ្គរាជទូតថ្មីនៃប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ។

នៅក្នុងជំនួបនោះ **សម្តេចក្រឡាហោម** បានសំដែងនូវការស្វាគមន៍ ចំពោះវត្តមានរបស់ ឯកឧត្តម ឯកអគ្គរាជទូតថ្មីប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបានយកឱកាសនេះថ្លែងអំណរគុណ ចំពោះរដ្ឋាភិបាល និងប្រជាជនជប៉ុន ដែលតែងតែយកចិត្តទុកដាក់ជួយឧបត្ថម្ភគាំទ្រដល់ដំណើរការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ជាពិសេសទៅលើវិស័យសេដ្ឋកិច្ច និងសង្គមចាប់តាំងពីក្រោយពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសរហូតមកដល់បច្ចុប្បន្ននេះ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍បញ្ជាក់ច្បាស់ថា៖ សមិទ្ធផលជាតិ ក៏ដូចជាជោគជ័យសំខាន់ៗលើការអភិវឌ្ឍសង្គមដែលកម្ពុជា សម្រេចបានរហូតមកដល់ពេលនេះពិតជាមិនអាចកាត់ផ្តាច់បានពីការចូលរួមចំណែកដ៏មានសារៈសំខាន់ពីសំណាក់រដ្ឋាភិបាល និងប្រជាជនជប៉ុននោះឡើយ។ មិនតែប៉ុណ្ណោះ ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ( កម្ពុជា-ជប៉ុន) អស់រយៈពេលជាច្រើនទសវត្សរ៍កន្លងមក ជាពិសេសមកដល់ពេលនេះប្រទេសទាំងពីរ ក៏បានលើកកម្ពស់កម្រិតទំនាក់ទំនង ជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ បន្ថែមទៀត ដែលចំណុចនេះ គឺជាផែនទីមួយដ៏មានសារៈសំខាន់ក្នុងការបន្តជំរុញដល់ការពង្រឹង និងពង្រីកកាន់តែខ្លាំងក្លាថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ។

ជាការឆ្លើយតបវិញ ឯកឧត្តម ឯកអគ្គរាជទូតជប៉ុន បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រសាសន៍លើកឡើងរបស់ **សម្តេចក្រឡាហោម** ដែលបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អ និងយូរលង់រវាងប្រទេសទាំងពីរកម្ពុជា-ជប៉ុន ។



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







លើសពីនេះទៀតជាមួយនិងការអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានធ្វើជាប្រធានកិច្ចប្រជុំអាស៊ាន ឆ្នាំ២០២២ កន្លងទៅ ប្រកបដោយជោគជ័យនោះ ឯកឧត្តម ឯកអគ្គរាជទូត ក៏បានជូនពរដល់ប្រទេសកម្ពុជា សូមឱ្យបន្តទទួលបានជោគជ័យត្រចះត្រចង់ថែមទៀត នៅក្នុងការរៀបចំនូវការប្រកួតព្រឹត្តិការណ៍កីឡាស៊ីហ្គេមដែលកម្ពុជា នឹងត្រូវធ្វើជាម្ចាស់ផ្ទះនាពេលឆាប់ៗខាងមុខនេះ ។

ឯកឧត្តម ឯកអគ្គរាជទូត ក៏បានជម្រាបជូន **សម្តេចក្រឡាហោម** អំពីដំណើរការនៃគម្រោងមួយចំនួនដែលជប៉ុន បានជួយគាំទ្រដល់កម្ពុជា ក្នុងនោះមានជាអាទិ៍ គឺការជួយគាំទ្រដល់គម្រោងអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ការជួយគាំទ្រដល់ការងារពាក់ព័ន្ធទៅនឹងការបោះឆ្នោតដែលជួយគាំទ្រតាមរយៈអង្គការ JICA ការជួយគាំទ្រដល់ការពង្រឹងភាពជាដៃគូ រវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែលគម្រោងនេះជួយគាំទ្រតាមរយៈអង្គការ UNDP និងគម្រោងពង្រឹងអភិបាលកិច្ចក៏ដូចជាតម្លាភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

មានប្រសាសន៍ ឆ្លើយតបវិញ **សម្តេចក្រឡាហោម** ក៏បានថ្លែងអំណរគុណចំពោះការជួយគាំទ្ររបស់ជប៉ុន ទៅលើគម្រោងនានា ដូចដែលបានលើកឡើងក្នុងនោះ **សម្តេចក្រឡាហោម** បានកត់សម្គាល់ទៅលើការគាំទ្រសំខាន់ៗដែលមានជាអាទិ៍៖ គឺការជួយរៀបចំនូវបញ្ជីឈ្មោះបោះឆ្នោតថ្មី ដែល **សម្តេច** ចាត់ទុកថានេះ គឺជាកិច្ចការមួយដ៏មានសារៈសំខាន់ដែលជាការជួយគាំទ្រមួយដល់ដំណើរការរៀបចំការបោះឆ្នោតនៅកម្ពុជា ។

**សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍សំដែងនូវក្តីសង្ឃឹមជឿជាក់ផងដែរថា៖ រដ្ឋាភិបាលជប៉ុននឹងនៅតែបន្តគាំទ្រដល់កិច្ចការទាំងនេះជាពិសេសទៅលើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលមកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជា បានឈានចូលដល់ដំណាក់កាលនៃការអនុវត្តនូវផែនការយុទ្ធសាស្ត្រជាតិដំណាក់កាលទី២ ហើយដែលបញ្ហានេះសម្តេចសង្ឃឹមថា ជប៉ុននឹងនៅតែបន្តគាំទ្រទៅលើការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យរដ្ឋបាលថ្នាក់ក្រោមជាតិ បន្តទៀត ។



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល


SOKIMEX INVESTMENT GROUP
ក្រុមហ៊ុន សុគីមិច អ៊ិនវេសមេន គ្រុប
SOKIMEX INVESTMENT GROUP CO., LTD.
SOKHA
សណ្ឋាគារ និងរមណីយដ្ឋានសុខា
Sokha Hotels & Resorts
+855 23 91 91 91
បូកគោ
ឋានសួគ៌ បូកគោ
THANSUR BOKOR
ក្រុមហ៊ុនបូកគោហ្វាម ឯ.ក
Bokor Farm Co.,Ltd.
+855 88 2636358 | +855 88 9494614
SOKIMEX
ស្ថានីយប្រេងឥន្ធនៈសុគីមិច
Sokimex Petroleum Station
SOKHA REAL ESTATE
ក្រុមហ៊ុនសុខារៀលអ៊ីស្តេត ឯ.ក
Sokha Real Estate Co., Ltd.
+855 98 200 777
#22 Kramuon Sar,Sangkat Phsar Thmey 2, Daun Penh, Phnom Penh Cambodia
Tel: (855) 23 998 918,Fax: (855) 23 998 920| E-mail: info@skmig.com | Website: www.skmig.com